## កម្មវិធីគាំទ្រសេវាអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

## (អេស្កាប់)

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

# ឯកសារបំប៉ន
# ស្តីពីការលើកកំពស់ការចូលរួមរបស់យុវវ័យ



# សម្រាប់ក្រុមគាំទ្រដល់ក្រុមយុវវ័យ
# នៅតាមសហគមន៍

ខែ វិច្ឆិកា ឆ្នាំ ២០០៩



# ក្រុមយុវវ័យនៅតាមសហគមន៍
# Community-Based Youth Group (CYG)



## I. សេចក្តីផ្តើម

ការស្រាវជ្រាវអំពីការអភិវឌ្ឍយុវវ័យ បានបង្ហាញឱ្យឃើញថាយុវវ័យមានសេចក្តីត្រូវការមួយចំនួន ដូចជាការគាំទ្រជាសំខាន់ ទីកន្លែងដែលគ្មានគ្រោះភ័យដើម្បីជួបជុំគ្នា ទំនាក់ទំនងល្អជាមួយមិត្តភក្តិ និងមនុស្សចាស់(មនុស្សពេញវ័យ) ឱកាសរៀនសូត្រនិងអនុវត្តបំណិនឬជំនាញដែលមាន ទៅតាមតួនាទីរៀងៗខ្លួន និងធ្វើសកម្មភាពដែលមានប្រយោជន៍នៅពេលទំនេរ។ ការចូលរួមដ៏ពិតប្រាកដរបស់យុវវ័យ នឹងផ្តល់ការរាប់អាន ការទទួលស្គាល់ ការទាក់ទាញការចាប់អារម្មណ៍ ព្រមទាំងការផ្តល់ឱកាសយ៉ាងពេញលេញឱ្យពួកគេបានទទួលបំណិនក្នុងការដោះស្រាយបញ្ហា ការសម្រេចចិត្ត និងការអភិវឌ្ឍសមត្ថភាព ។ ការចូលរួមនេះនឹងបង្កើតនូវទំនាក់ទំនងល្អ បង្កើនទំនុកចិត្តចំពោះខ្លួនឯង ហើយអាចបញ្ចេញសមត្ថភាពជាសមាជិកសហគមន៍ដែលមានការទទួលខុសត្រូវ និងការចូលរួម។

កម្មវិធីអេស្កាប់ជឿជាក់ថា ការបង្កើតក្រុមយុវវ័យនៅតាមសហគមន៍ ជាយន្តការមួយក្នុងការគាំទ្រការចូលរួមដ៏ពិតប្រាកដ ដែលក្នុងនោះយកការប្រើធនធានមូលដ្ឋានជាសំខាន់ ដែលអាចបង្កើនការចូលរួមរបស់ពួកគេជាពលរដ្ឋ និងជួយពង្រឹងកម្លាំងសង្គមជាតិទាំងមូល។ នេះក៏ជាយុទ្ធវិធីមួយ ក្នុងការលើកកំពស់ការអប់រំ និងការអភិវឌ្ឍសាលារៀន/សហគមន៍ ដែលយុវវ័យអាចនាំមុខកុមារ ធ្វើការដោះស្រាយបញ្ហា និងកង្វល់ដែលកុមារមាន។ ម៉្យាងទៀត វិធីនេះក៏អាចជួយយុវវ័យឱ្យមានការអភិវឌ្ឍបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនដើម្បីឈានទៅដោះស្រាយបញ្ហានៅក្នុងសហគមន៍បាន។

## II. គោលបំណងរួម

បណ្តាញក្រុមយុវវ័យនៅតាមសហគមន៍ (CYG) ផ្តល់ឱកាសឱ្យមនុស្សវ័យក្មេង ធ្វើការជាក្រុមជាមួយអ្នកដែលមានវ័យប្រហាក់ប្រហែលគ្នា ដើម្បីអភិវឌ្ឍផែនការ និងអនុវត្តផែនការសកម្មភាពនោះ ដើម្បីជាប្រយោជន៍ដល់សហគមន៍។ ក្រុមយុវវ័យនៅតាមសហគមន៍អាចបង្កើនភាពក្លាហាន ក្លៀវក្លា មានទំនុកចិត្ត (តាមរយៈការពង្រឹងចំណុចខ្លាំងដែលគេមានស្រាប់ រួមទាំងអំណោយទាន ថាមពល និងការច្នៃប្រឌិត) កាត់បន្ថយភាពប្រថុយនឹងគ្រោះថ្នាក់ផ្សេងៗ ហើយលើកកំពស់សមត្ថភាព និងផ្តល់កម្លាំងស្មារតីនិងការតាំងចិត្តដល់យុវវ័យដែលចូលរួមក្នុងបណ្តាញការងារនេះ។

## III. និសដៅលំអិត

- រៀបចំបង្កើតក្រុមមួយ ដែលយុវវ័យអាចរៀនសូត្រ និងអភិវឌ្ឍន៍បំណិនផ្ទាល់ខ្លួន ទាក់ទងនឹងការងារសង្គម និងការអភិវឌ្ឍ ។
- យុវវ័យនិងកុមារបានធ្វើការរួមគ្នា ធ្វើផែនការ និងអនុវត្តគម្រោងផែនការ ដែលជួយគាំទ្រកុមារ ឱ្យជំនះលើឧបសគ្គនានា (ដែលទាក់ទងនឹងវប្បធម៌ ភាសា ឃេនឌ័រ ជាដើម) ដែលធ្វើឱ្យរាំងស្ទះដល់ការសិក្សា ហើយជួយឱ្យកុមារនៅបន្តការសិក្សាបាន និងរៀនបានល្អប្រសើរជាងមុន ។

ការចូលរួមពិប្រាកដ ឈានពីភាពនិមិត្តរូបនិយម (ដូចជាគ្រាន់តែមានឈ្មោះក្នុងក្រុមដោយពុំមានសមត្ថភាព ឬការសម្រេចចិត្តពិតប្រាកដ) ឆ្ពោះទៅរកលំនាំ មួយដែលយុវវ័យមានការចូលរួមក្នុងការសម្រេចចិត្ត ហើយដែលការសម្រេចចិត្តនោះធ្វើឱ្យមានឥទ្ធិពល លើសុខុមាលភាពរបស់ពួកគេ ក្នុងបរិស្ថានមួយដែលពួកគេអាចមានឱកាសរៀនសូត្រពីបទពិសោធន៍ របស់មនុស្សពេញវ័យ ។

*(A Guide to Youth Friendly Practices, The City of Calgary)*

## IV. រចនាសម្ព័ន្ធក្រុមយុវវ័យនៅតាមមូលដ្ឋាន

ក្រុមយុវវ័យនៅតាមសហគមន៍ អាចនឹងមានសមាជិកប្រមាណពី១៥ ទៅ ២០នាក់ក្នុងមួយក្រុម ។ សមាជិកក្រុមអាចជាយុវវ័យដែលកំពុងរៀននៅអនុវិទ្យាល័យ ឬជាយុវជន/យុវតីដែលឈប់រៀន ហើយកំពុងនៅក្រៅសាលា ដែលមានឆន្ទៈចង់រៀនអ្វីដែលថ្មីពីកម្មវិធី ដើម្បីអភិវឌ្ឍខ្លួនឯង និងអភិវឌ្ឍអ្នកដទៃ ហើយជាអ្នកស្ម័គ្រចិត្តចំណាយពេលវេលា ធ្វើការជាមួយកុមារដែលមកពីក្រុមជនជាតិខុសៗគ្នា ដែលបច្ចុប្បន្នកំពុងរៀននៅក្នុងសាលា ។ យើងរំពឹងថា ពួកគេជាមនុស្សវ័យក្មេងដែលមានការយល់ដឹងអំពីលក្ខណៈរបស់កុមារ ពិសេសកុមារី ដែលមកពីក្រុមជនជាតិ និងកុមារពិការ/មានជម្ងឺ ។

សមាជិកទាំងអស់នៃក្រុមយុវវ័យត្រូវដាក់ពាក្យសុំ ហើយនឹងត្រូវបានធ្វើការជ្រើសរើសដោយផ្អែកទៅតាមលក្ខណៈវិនិច្ឆ័យ ។ ប្រធាន និងអនុប្រធាននឹងត្រូវបានជ្រើសរើសដោយធ្វើការបោះឆ្នោត ។ ក្រុមយុវយ័យនឹងត្រូវបានទទួការគាំទ្រផ្នែកបច្ចេកទេស និងការពិនិត្យតាមដាន ដោយក្រុមគាំទ្រដល់ក្រុមយុវវ័យ ។ ក្រុមយុវវ័យអាចមានសមាសភាពដូចខាងក្រោម:




អនុប្រធានអាចមានលើសពីពីរនាក់ ទៅតាមវិសាលភាពនៃក្រុមដែលបង្កើតឡើង។ ឧទាហរណ៍ បើក្រុមមួយ មានសមាជិក ២០នាក់  អនុប្រធានអាចមានចាប់ពី៣នាក់ឡើងទៅ ប្រសិនបើមានការចាំបាច់។

## V. លក្ខណៈវិនិច្ឆ័យសម្រាប់ក្រុមយុវវ័យនៅតាមមូលដ្ឋាន *(CYG)*

យុវវ័យនៅក្រៅសាលា ដែលបានឈប់រៀន ឬយុវជនកំពុងរៀននៅអនុវិទ្យាល័យដែលៈ

- រស់នៅក្នុងភូមិចំណុះឱ្យសាលារៀនគោលដៅ
- ទទួលការរាប់អានពីអ្នកភូមិ
- មានពេលវេលាគ្រប់គ្រាន់ ក្នុងការស្ម័គ្រចិត្តចូលរួមជួយក្នុងការងារអភិវឌ្ឍ
- មានការចាប់អារម្មណ៍ធ្វើការជាមួយកុមារ ជាពិសេសកុមារដែលមកពីក្រុមជនជាតិផ្សេងៗខុសៗគ្នា
- មានឥរិយាបទល្អៈ
  - មានការយល់ដឹងពីលក្ខណៈនិងតម្រូវការរបស់កុមារ
  - មានការយល់ដឹងនិងយកចិត្តទុកដាក់អំពីបញ្ហាយេនឌ័រ
  - គ្មានការរើសអើង
  - ឱ្យតម្លៃលើការចូលរួម
  - មានការច្នៃប្រឌិត និងមានឆន្ទៈចង់រៀនអ្វីដែលថ្មី
- ជាមនុស្សដែលបង្ហាញគំរូល្អដល់កុមារ

## VI. ការទទួលខុសត្រូវនិងភារកិច្ចរបស់ក្រុមយុវវ័យ

មនុស្សវ័យក្មេងអាចធ្វើអ្វីៗបានដូចគ្នានឹងមនុស្សពេញវ័យ  ប្រសិនបើគេបានទទួលការគាំទ្រត្រឹមត្រូវ និងមានធនធានគ្រប់គ្រាន់។ គេអាចធ្វើផែនការ ដឹកនាំការប្រជុំ ចែករំលែកការងារក្នុងក្រុម ធ្វើបទបង្ហាញ

ផ្សេងៗ រៀបចំដំណើរការសិក្ខាសាលា ព្រមទាំងចលនារកថវិកា ជាដើម ។ល ។ គ្រប់ៗគ្នាសុទ្ធតែមានចំណុចដែលអាចរួមចំណែកបាន ។ ដោយមានការលើកទឹកចិត្ត និងការគាំទ្រជាបន្តបន្ទាប់ យើងរំពឹងថាក្រុមការងារយុវវ័យអាចបំពេញតួនាទី និងភារកិច្ចដូចខាងក្រោម៖

១. ប្រជុំជាមួយសមាជិកក្នុងក្រុម (និងជាមួយកុមារ) ដើម្បីពិភាក្សាបញ្ហានិងធ្វើផែនការ ។

២. ផ្តល់ការណែនាំ និងលើកកំពស់ការយល់ដឹង ទាក់ទងនឹងការងារអប់រំ សង្គម និងសុខភាព (ឧ. អំពើហិង្សាក្នុងគ្រួសារ អំពើជួញដូរកុមារ យេនឌ័រនិងភាពប្លែកពីគ្នា តួនាទីនៃវប្បធម៌នៅក្នុងការអប់រំ ការចៀសវាងការរាលដាលនៃជម្ងឺអេដស៍ និងគ្រឿងញៀនជាដើម ។ល)

៣. ជួយកុមារឱ្យពួកគេបានដឹងថា៖

- o ពួកគេត្រូវជួយសំអាតទីធ្លាសាលាដោយរើសសម្រាមដាក់ក្នុងធុងសម្រាម ។
- o ពួកគេត្រូវដាក់ផែនការ ដាំដើមឈើ នៅពេលណាមួយ និងថែទាំដើមឈើ ។
- o ពួកគេត្រូវពិនិត្យមើលបរិស្ថានសាលារៀន និងលំនៅដ្ឋាន ។

៤. ចាត់ចែងក្លឹបសិក្សា ក្រៅម៉ោងរៀន ។

៥. ជួយសិស្សដែលត្រូវឪពុកម្តាយឱ្យជួយការផ្ទះច្រើន តាមរយៈការជួយបង្រៀនបន្ថែមនៅពេលទំនេរ ។

៦. រៀបចំសកម្មភាពកំសាន្តផ្សេងៗជាមួយកុមារ និងដើម្បីកុមារ ដូចជាសកម្មភាសពកីឡា សិល្បៈ និងសកម្មភាពស្រាវជ្រាវផ្សេងៗ ដើម្បីស្វែងយល់ពីសហគមន៍ ។

៧. រៀបចំនិងចាត់ចែងទិវាយុវវ័យ {Youth Activity Day (YAD)} ដោយឱ្យកុមារចូលរួមបង្ហាញនូវអ្វីដែលពួកគេបានធ្វើ ឬបានរៀនពីសកម្មភាពដែលពួកគេបានចូលរួមកន្លងមក ។

៨. ចូលរួមក្នុងសកម្មភាពបង្រៀនសិស្សរៀនយឺត ដោយសហការជាមួយគ្រូបង្រៀន ។

៩. ចុះតាមផ្ទះសិស្សដែលអវត្តមាន និងសិស្សបោះបង់ ដោយសហការជាមួយគ្រូបន្ទុកថ្នាក់ ។

១០. សរសេររបាយការណ៍ឬកត់ត្រាករណីសិក្សា ឬលទ្ធផលល្អៗ ពីសកម្មភាពការងាររបស់ពួកគេ ។

## VII. យុទ្ធវិធីការបង្កើតក្រុមយុវវ័យនៅតាមសហគមន៍ គម្រោង

ជំហានក្នុងការបង្កើនការចូលរួមរបស់យុវវ័យ និងការបង្កើតយុវវ័យនៅតាមសហគមន៍៖

១. រកគោលនយោបាយ និង គោលការណ៍ណែនាំផ្សេងៗទាក់ទងនឹងការបង្កើតក្រុមយុវវ័យ ឬសមាគមសិស្ស ។

២. ស្វែងរកអង្គការដៃគូ ដែលមានបទពិសោធន៍ក្នុងការធ្វើការជាមួយយុវ័យ ដើម្បីរៀបចំចងក្រងឯកសារ និងអនុវត្តកម្មវិធីដែលមានការចូលរួមពីយុវវ័យ ជាមួយគ្នា ។

៣. ធ្វើផែនការជាមួយដៃគូ៖

- o តើដំណើរការនៃការរៀបចំបង្កើតក្រុមយុវវ័យនៅមូលដ្ឋាន ដូចម្តេចខ្លះ? តើរៀបចំរចនាសម្ព័ន្ធដូចម្តេច?
- o តើយើងចង់ឱ្យយុវវ័យមានការចូលរួមកម្រិតណា?
- o តើយន្តការនៃការទទួលខុសត្រូវអ្វីខ្លះ សម្រាប់ក្រុមយុវវ័យ ហើយទទួលខុសត្រូវដូចម្តេច?
- o តើការគាំទ្របែបណាខ្លះដែលក្រុមយុវវ័យត្រូវការ ដើម្បីអភិវឌ្ឍសមត្ថភាពពួកគេ?
- o តើត្រូវផ្តល់ការណែនាំ និងជួយគាំទ្រពួកគេដោយរបៀបណា?
- o ប្រសិនបើដំណើរការក្រុមយុវវ័យមានបញ្ហាកើតឡើង តើត្រូវដោះស្រាយដោយរបៀបណា?

៤. រៀបចំក្រុមពិភាក្សា (focus group discussions) ជាមួយសហគមន៍ និងយុវវ័យ ដើម្បីសម្រេចជ្រើសរើសទីកន្លែង ធ្វើកម្មវិធីសាលល្បង ។

៥. ក្នុងភាពជាដៃគូជាមួយយុវវ័យ កំណត់រកអ្នកដែលមានលក្ខណៈសម្បត្តិឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស ហើយបង្កើតតួនាទីនិងភារកិច្ចសម្រាប់ក្រុមយុវវ័យ ។

៦. បង្កើតអាំងឌីកាទ័រ ទាក់ទងនឹងការចូលរួមរបស់យុវវ័យ ជាមួយក្រុមយុវវ័យ ថាតើក្នុងពេលវេលាមួយដែលកំណត់ ពួកគេចង់សម្រេចអ្វីខ្លះ? (ធានាឱ្យមានការចនធានសមស្រប ដើម្បីសម្រេចអាំងឌីកាទ័រទាំងនេះ) ។

៧. ជួយក្រុមយុវវ័យ ក្នុងការបង្កើតផែនការសកម្មភាព និងគម្រោងថវិកា ។

៨. ជួយអភិវឌ្ឍសមត្ថភាពក្រុមយុវវ័យ (តាមរយៈការបើកសិក្ខាសាលាទៅតាមតម្រូវការរបស់ពួកគេ) ដើម្បីធានាឱ្យពួកគេអាចអនុវត្តផែនការដោយរលូន និងប្រកបដោយជោគជ័យ ។

៩. ពិនិត្យតាមដាន និងផ្តល់ការគាំទ្រជាប្រចាំដល់ក្រុមយុវវ័យ ។

## VIII. លក្ខណៈវិនិច្ឆ័យជ្រើសរើសភូមិគោលដៅសម្រាប់សាកល្បងបង្កើតក្រុមយុវវ័យ

ភូមិទាំងឡាយណាដែលមានកុមារចូលរៀននៅសាលាគាំទ្រដោយកម្មវិធីអេស្កាប់ ហើយដែល:

- o មានក្រុមគោលដៅជាក្រុមសកម្ម មានចិត្តចង់ជួយគាំទ្រដល់ក្រុមយុវវ័យនៅតាមសហគមន៍ ហើយមានទំនាក់ទំនងល្អជាមួយអង្គការដែលទទួលខុសត្រូវក្រុមយុវវ័យ ។
- o មានការចូលរួម និងគាំទ្រយ៉ាងសកម្មពីសហគមន៍ /មាតាបិតា ។
- o មានកុមារជាច្រើន ដែលមានបញ្ហាក្នុងការសិក្សា (ទាក់ទងនឹងភាសា និងវប្បធម៌ ជាដើម) ។

o មានមនុស្សវ័យក្មេង និងយុវជនជាច្រើន ដែលមានសក្តានុពល និងឆន្ទៈ ក្នុងការអភិវឌ្ឍខ្លួន ចង់រៀនសូត្រអ្វីដែលថ្មី និងចង់រួមចំណែកអភិវឌ្ឍសហគមន៍របស់ខ្លួន ជាពិសេសចង់ធ្វើការជាមួយកុមារ ។

## VIII. គម្រោងថវិកាសម្រាប់ដំណើរការក្រុមយុវវ័យ

| | សកម្មភាព | សកម្មភាពរង | | សរុប |
|---|---|---|---|---|
| ១ | រៀបចំបង្កើតក្រុមយុវវ័យ | ប្រជុំផ្សព្វផ្សាយដល់សហគមន៍ | $1.5x 2 នាក់ x 1 ថ្ងៃ =$3<br>$.5x20=$10 | $13.00 |
| | | រៀបចំក្រុមពិភាក្សា ជាមួយសហគមន៍ | $1.5x x 2 នាក់ x 1 ថ្ងៃ =$3 | $3.00 |
| | | ប្រជុំជាមួយយុវវ័យ ជ្រើសរើសយុវជនស្ម័គ្រចិត្ត | $1.5x 2 នាក់ x 1 ថ្ងៃ =$3<br>អាហារសម្រន់:$.5x30 នាក់ =$15<br>សម្ភារ( ក្រដាស ហ្វឺត..): $5.00 | $23.00 |
| | | | **សរុបរង** | **$39.00** |
| ២ | សកម្មភាពកសាងសមត្ថភាពយុវវ័យ | បណ្តុះបណ្តាលយុវវ័យពីរបៀបធ្វើផែនការសកម្មភាព | $1.5 x 2 នាក់ x 1 ថ្ងៃ =$3<br>អាហារសម្រន់:$.5x20 នាក់ = $10<br>សម្ភារ( ក្រដាស ហ្វឺត..): $5.00 | $18.00 |
| | | វគ្គបំប៉នផ្សេងៗ ដែលទាក់ទងនឹងការអនុវត្តរបស់យុវវ័យ | $1.5x x 2 នាក់ x 5 លើក= $15<br>អាហារសម្រន់:$.5x20នាក់ x5លើក = $50<br>សម្ភារ( ក្រដាស ហ្វឺត..):<br>$5.00 x 5 លើក= $25 | $90.00 |
| | | | **សរុបរង** | **$108** |
| ៣ | ការអនុវត្តផែនការសកម្មភាព | សកម្មភាពទីមួយៗ ផ្អែកតាមលទ្ធផលនៃផែនការសកម្ម-ភាព ហើយគិតជាកញ្ចប់ទឹកប្រាក់សរុបក្នុងមួយខែ | $30x 5 ខែ =$150 | $150 |
| | | | **សរុបរង** | **$ 150** |
| ៤ | សកម្មភាពពិនិត្យតាមដាន | សកម្មភាពពិនិត្យតាមដានការអនុវត្តរបស់យុវវ័យ | $1.5x x 2 នាក់ x 5 លើក= $15 | $15 |
| | | | **សរុបរង** | **$ 15** |
| | | | **សរុប** | **$ 312.00** |

**ឧបសម្ព័ន្ធទី១:**



## ការធ្វើផែនការជាមួយអង្គការដៃគូ
## ក្នុងការបង្កើតក្រុមយុវវ័យនៅតាមសហគមន៍

- o បុគ្គលិកគម្រោងរៀបចំការប្រជុំជាមួយបុគ្គលិកអង្គការដៃគូ ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតក្រុមយុវវ័យនៅតាមសហគមន៍ និងផែនការការងារសម្រាប់ក្រុមនេះ នៅពេលខាងមុខ ។
- o អ្នកសម្របសម្រួលពន្យល់ថា គម្រោងអេស្កាប់កំពុងគិតអំពីការធ្វើការជាមួយយុវវ័យ ដោយពង្រឹងបណ្តាញយុវវ័យដែលមានស្រាប់ឬបង្កើតក្រុមថ្មី ដើម្បីជាយន្តការមួយក្នុងសហគមន៍ សំដៅរួមចំណែកជួយអភិវឌ្ឍសហគមន៍/សាលារៀន ហើយដែលការងារនេះដឹកនាំដោយយុវវ័យ ក្នុងការជួយដាស់តឿនកុមារ និងជួយដល់ពួកគេក្នុងការដោះស្រាយកង្វល់ឬបញ្ហា ដែលកុមារជួបប្រទះក្នុងការសិក្សា ។ ពោលគឺ តាមរយៈអន្តរាគមន៍នេះ យុវវ័យនឹងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍខ្លួនឯងផង និងចូលរួមជួយដោះស្រាយបញ្ហាដែលកើតមាននៅក្នុងសហគមន៍ផង ។
- o អ្នកសម្របសម្រួលឱ្យសិក្ខាកាមពិភាក្សា លើសំណួរដូចខាងក្រោម:

  ១-តើអ្នកណាខ្លះ ដែលគួរជាសមាជិកក្រុមយុវវ័យ (ក្រុមគោលដៅ)?

  ២-តើអ្នកយល់ថាការបង្កើតក្រុមយុវវ័យ មានប្រយោជន៍ឬទេ? បើមាន តើហេតុអ្វី (គោលដៅ)?

  ៣-តើអ្នកគិតថាក្រុមយុវវ័យគួរមានតួនាទីអ្វីខ្លះ (តួនាទី និងភារកិច្ច)?
- o សិក្ខាកាមពិភាក្សាគ្នាក្នុងក្រុមតូច ហើយសរសេរយោបល់ដែលបានពីការពិភាក្សា នៅលើផ្ទាំងក្រដាសធំ ។
- o តំណាងក្រុមឡើងបង្ហាញលទ្ធផលពិភាក្សារបស់ក្រុមខ្លួន នៅក្នុងក្រុមធំ ។ យើងរំពឹងថា ក្រុមនីមួយៗមើលឃើញអំពីផលប្រយោជន៍នៃការបង្កើតក្រុមយុវវ័យនៅតាមសហគម៌ ។

> សំណួរទី ១:អាចមានជម្រើសច្រើនសម្រាប់ក្រុមគោលដៅ:
>
> - o អាចជាយុវជនកំពុងរៀន ឬយុវជនក្រៅសាលា
> - o អាចជាយុវជនកំពុងរៀន ឬយុវជនក្រៅសាលា ជនជាតិចម្រុះដូចជាខ្មែរ និងខ្មែរឥស្លាម ជាដើម(លក្ខណៈដទៃទៀត សូមមើលលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសសមាជិកក្រុមយុវវ័យ នៅក្នុងទំព័រទី៣ ដែលនឹងត្រូវពិភាក្សានៅចំនុចខាងក្រោយ) ។

| |
|---|
| សំណួរទី ២ និង៣: សូមមើលចំណុចទី *III* ដល់ *IV* ក្នុងទំព័រ១-៤។ |

- ក្រោយពេលដែលដែលសិក្ខាកាមយល់ថាក្រុមយុវវ័យមានប្រយោជន៍ អ្នកសម្របសម្រួលបំផុសគំនិតក្នុងក្រុមធំ ដោយសួរសំណួរខាងក្រោមជាបន្តទៀតៈ

  ១-តើលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសសមាជិកក្រុមយុវវ័យគួរមានអ្វីខ្លះ?

  ២-តើគួររៀបចំដូចម្ដេច(រចនាសម្ព័ន្ធ)?តើគួរមានសមាជិកប៉ុន្មាននាក់ក្នុងមួយក្រុម ហើយក្រុមនេះគួរធ្វើការជាមួយអ្នកណា ហើយធ្វើរបាយការណ៍ទៅអ្នកណា?

  ៣-តើគួរផ្សារភ្ជាប់បណ្ដាញនេះជាមួយសាលារៀន និងសហគមន៍ដូចម្ដេច?

  ៤-តើគួរមានការលើកទឹកចិត្តដូចម្ដេចខ្លះ ចំពោះក្រុមនេះ នៅពេលគេខិតខំធ្វើការ?

  ៥-តើគម្រោងនេះគួរមានរយៈពេលប៉ុន្មាន?

  ៦-តើគម្រោងនេះអាចមាននិរន្តរភាពដោយរបៀបណា?

- កត់ត្រាគំនិតទាំងអស់ដែលបានពីក្រុមធំ ដើម្បីយកទៅប្រើប្រាស់ក្នុងការធ្វើផែនការជាបន្តទៀត។
- ក្នុងក្រុមធំ កំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ទីតាំងគោលដៅ។
- បូកសរុបមតិយោបល់ទាំងអស់ ហើយកត់ត្រាលទ្ធផលនៃការប្រជុំ។

<u>កំណត់សំគាល់:</u> កម្មវិធីរំពឹងថា យុវវ័យដែលបានដាក់ពាក្យចង់ចូលរួមក្នុងកម្មវិធីនេះ នឹងបានទទួលការយល់ដឹងយ៉ាងច្បាស់លាស់នូវគោលបំណងនិងផលប្រយោជន៍ ក្នុងការចូលរួមជាសមាជិកក្រុមយុវវ័យ (សូមមើលត្រង់មូលហេតុ និងផលប្រយោជន៍ដែលទទួលបានពីការចូលរួមរបស់យុវវ័យ ទំព័រទី១៦)។ ពុំនោះទេ ពួកគេនឹងរំពឹងគិតថា គេនឹងបានទទួលកម្រៃផ្សេងៗពីកម្មវិធី ដូចជាប្រាក់កាសជាដើម។ ការធ្វើទៅតាមក្ដីរំពឹងនេះ នឹងធ្វើឱ្យប្រាសចាកពីគោលការណ៍នៃ"ការចូលរួមដ៏ពិតប្រាកដ" និង "ការផ្ទេរអំណាចដល់យុវវ័យ" ដែលក្នុងនោះសំដៅជាពិសេសទៅលើការទាក់ទាញការចូលរួមតាមរយៈការអភិវឌ្ឍសមត្ថភាពរបស់យុវវ័យ និងការកសាងធនធាននៅក្នុសហគមន៍ ជាជាងការទាក់ទាញតាមរយៈប្រាក់កាស និងសម្ភារផ្សេងៗដែលពុំបង្ហាញ នូវនិរន្តរភាព ឬពុំបន្សល់នូវធនធានមនុស្ស នៅពេលដែលកម្មវិធីត្រូវបានបញ្ចប់នៅមូលដ្ឋាននោះ។

**<u>ឧបសម្ព័ន្ធទី២:</u>**

# Educational Support for Children in Underserved Populations

## សំណួរនាំផ្លូវសម្រាប់ក្រុមពិភាក្សា

## ឧបករណ៍ដើម្បីធ្វើការជ្រើសរើសទីតាំងក្នុងការបង្កើតយុវវ័យ

**ការណែនាំ:**

ការសម្ភាសនេះ អាចមានរយៈពេលប្រម៉ាណជាពីរម៉ោងជាមួយៈ

១) សមាជិសហគមន៍ ( ជាក្រុមចម្រុះ ដែលមាន ជន ជាតិ ភេទ កម្រិតវប្បធម៌ និងអាយុខុសៗគ្នា) ។

២) យុវវ័យនៅក្នុងសហគមន៍ ដែលជាក្រុមចម្រុះ ដូចខាងលើ ។

ក្រុមសម្ភាសនីមួយៗគួរមានគ្នាប្រមាណ៨ នាក់ ទៅ១០នាក់ ក្នុងមួយក្រុម ។

ក្រោយពីសម្ភាសរួចអ្នកសម្របសម្រួលត្រូវដាក់ពិន្ទុទៅលើចំណុចនីមួយៗនៅក្នុងជួរខាងស្តាំ ដោយគូសរង្វង់លើពិន្ទុណាមួយ ទៅតាមចម្លើយរបស់ក្រុមដែលបានផ្តល់ឱ្យ ។ នៅពេលសម្ភាសចប់ ត្រូវសរុបពិន្ទុ ហើយសរសេរពិន្ទុសរុបនោះ នៅក្នុងចន្លោះក្នុងប្រអប់ផ្នែកខាងលើនៃទម្រង់នេះ ។

| | |
|---|---|
| ឈ្មោះឃុំ : ______________________ | ឈ្មោះភូមិ:______________________ |
| កម្រង: ______________________ | ឈ្មោះអ្នកវាយតម្លៃ: ________________ |
| កាលបរិច្ឆេទ: ____________________ | ពិន្ទុសរុប:________________ |

| សំណួរនាំផ្លូវសម្រាប់ក្រុមពិភាក្សា | | ពិន្ទុ |
|---|---|---|
| 1 | តើអ្នកដឹងថា មានសមាគមនៅតាមភូមិរបស់អ្នក ដូចជាសមាគមយុវជន សមាគមស្ត្រី សមាគមសាសនា ឬក៏ក្រុមបង្គោលអ្វី ដែរឬទេ? បើមាន សូមបញ្ជាក់ផងថាតើជាក្រុម ឬ សមាគមអ្វី?<br><u>សមាជិកទី១:</u> ☐បាទ /ចាស ______________________ ☐ទេ<br><u>សមាជិកទី២:</u> ☐បាទ /ចាស ______________________ ☐ ទេ<br><u>សមាជិកទី៣:</u> ☐បាទ /ចាស ______________________ ☐ទេ<br><u>សមាជិកទី៤:</u>☐បាទ /ចាស ______________________ ☐ទេ<br><u>សមាជិកទី៥:</u> ☐បាទ /ចាស _______ ______________ ☐ ទេ<br><u>សមាជិកទី៦:</u> ☐បាទ /ចាស ______________________ ☐ទេ<br><u>សមាជិកទី៧:</u> ☐បាទ /ចាស ______________________ ☐ ទេ<br><u>សមាជិកទី៨:</u> ☐បាទ /ចាស ______________________ ☐ទេ | 10 9<br>8 7 6<br>5 4 3<br>2 1 0 |

| | | |
|---|---|---|
| | <u>សមាជិកទី៩:</u> ☐បាទ /ចាស ________________________ ☐ ទេ<br><u>សមាជិកទី១០:</u> ☐បាទ /ចាស ________________________☐ទេ<br>យោបល់ ឬសំណូមពររបស់អ្នកឆ្លើយ: ________________________ | |
| **2** | តើអ្នកដឹងថា តើក្រុមឬសមាគមនោះ ជួបប្រជុំគ្នាប៉ុន្មានដងក្នុង១ខែ? *(បើសំណួរទី១ គ្រប់គ្នាឆ្លើយថាទេ មកដល់សំណួរនេះគឺរំលងចោល ដោយមិនចាំបាច់សួរ)*<br><u>សមាជិកទី១:</u> ☐ច្រើនជាងម្តងក្នុង១ខែ ☐ម្តងក្នុង១ខែ ☐ តិចជាងម្តងក្នុង១ខែ ☐ មិនដែល<br><u>សមាជិកទី២:</u> ☐ច្រើនជាងម្តងក្នុង១ខែ ☐ម្តងក្នុង១ខែ ☐ តិចជាងម្តងក្នុង១ខែ ☐ មិនដែល<br><u>សមាជិកទី៣:</u> ☐ច្រើនជាងម្តងក្នុង១ខែ ☐ម្តងក្នុង១ខែ ☐ តិចជាងម្តងក្នុង១ខែ ☐ មិនដែល<br><u>សមាជិកទី៤:</u> ☐ច្រើនជាងម្តងក្នុង១ខែ ☐ម្តងក្នុង១ខែ ☐ តិចជាងម្តងក្នុង១ខែ ☐ មិនដែល<br><u>សមាជិកទី៥:</u> ☐ច្រើនជាងម្តងក្នុង១ខែ ☐ម្តងក្នុង១ខែ ☐ តិចជាងម្តងក្នុង១ខែ ☐ មិនដែល<br><u>សមាជិកទី៦:</u> ☐ច្រើនជាងម្តងក្នុង១ខែ ☐ម្តងក្នុង១ខែ ☐ តិចជាងម្តងក្នុង១ខែ ☐ មិនដែល<br><u>សមាជិកទី៧:</u> ☐ច្រើនជាងម្តងក្នុង១ខែ ☐ម្តងក្នុង១ខែ ☐ តិចជាងម្តងក្នុង១ខែ ☐មិនដែល<br><u>សមាជិកទី៨:</u> ☐ច្រើនជាងម្តងក្នុង១ខែ ☐ម្តងក្នុង១ខែ ☐ តិចជាងម្តងក្នុង១ខែ ☐ មិនដែល<br><u>សមាជិកទី៩:</u> ☐ច្រើនជាងម្តងក្នុង១ខែ ☐ម្តងក្នុង១ខែ ☐ តិចជាងម្តងក្នុង១ខែ ☐មិនដែល<br><u>សមាជិកទី១០:</u> ☐ច្រើនជាងម្តងក្នុង១ខែ ☐ម្តងក្នុង១ខែ☐ តិចជាងម្តងក្នុង១ខែ☐ មិនដែល<br>យោបល់ ឬសំណូមពររបស់អ្នកឆ្លើយ:<br>________________________________________ | 30 29<br>28 27<br>26 25<br>24 23<br>22 21<br>20 19<br>18 17<br>16 15<br>14 13<br>12 11<br>10 9 8<br>7 6 5<br>4 3 2<br>1 0 |
| **3** | តើអ្នកអាចរៀបរាប់ឱ្យយើងបានដឹងថា តើក្រុមឬសមាគមនោះសកម្មចូលរួមក្នុងការងារសង្គមយ៉ាងណា ដែរ? *(បើសំណួរទី១ គ្រប់គ្នាឆ្លើយថាទេមកដល់សំណួរនេះគឺរំលងចោល ដោយមិនចាំបាច់សួរ)*<br><u>សមាជិកទី១:</u> ☐ សកម្មណាស់ ☐សកម្មដែរ ☐ មិនសកម្មទេ<br><u>សមាជិកទី២:</u> ☐សកម្មណាស់ ☐សកម្មដែរ ☐ មិនសកម្មទេ<br><u>សមាជិកទី៣:</u> ☐សកម្មណាស់ ☐សកម្មដែរ ☐ មិនសកម្មទេ<br><u>សមាជិកទី៤:</u> ☐សកម្មណាស់ ☐សកម្មដែរ ☐ មិនសកម្មទេ<br><u>សមាជិកទី៥:</u> ☐សកម្មណាស់ ☐សកម្មដែរ ☐ មិនសកម្មទេ<br><u>សមាជិកទី៦:</u> ☐សកម្មណាស់ ☐សកម្មដែរ ☐ មិនសកម្មទេ<br><u>សមាជិកទី៧:</u> ☐សកម្មណាស់ ☐សកម្មដែរ ☐ មិនសកម្មទេ<br><u>សមាជិកទី៨:</u> ☐សកម្មណាស់ ☐សកម្មដែរ ☐ មិនសកម្មទេ | 20 19<br>18 17<br>16 15<br>14 13<br>12 11<br>10 9 8<br>7 6 5<br>4 3 2<br>1 0 |

| | | |
|---|---|---|
| | <u>សមាជិកទី៩:</u> ☐សកម្មណាស់ ☐សកម្មដែរ ☐ មិនសកម្មទេ<br><u>សមាជិកទី១០:</u> ☐សកម្មណាស់ ☐សកម្មដែរ ☐ មិនសកម្មទេ<br>យោបល់ ឬសំណូមពររបស់អ្នកឆ្លើយ:<br>________________________________________ | |
| **4** | តើអ្នកដឹងថា រៀងរាល់ថ្ងៃយុវជន និងមនុស្សវ័យក្មេង( មនុស្សប្រុស) នៅក្នុងភូមិធ្វើអ្វីខ្លះ?<br><u>សមាជិកទី១:</u> ☐ធ្វើស្រែចំការ ☐រកត្រី ☐ធ្វើការឱ្យគេយកប្រាក់កម្រៃ ☐នៅធ្វើការផ្ទះ<br>☐ដើរលេងជាមួយមិត្តភក្តិ ☐ផ្សេងៗ( សូមបញ្ជាក់) :____________<br><u>សមាជិកទី២:</u> ☐ធ្វើស្រែចំការ ☐រកត្រី ☐ធ្វើការឱ្យគេយកប្រាក់កម្រៃ ☐នៅធ្វើការផ្ទះ<br>☐ដើរលេងជាមួយមិត្តភក្តិ ☐ផ្សេងៗ( សូមបញ្ជាក់) :____________<br><u>សមាជិកទី៣:</u>☐ធ្វើស្រែចំការ ☐រកត្រី ☐ធ្វើការឱ្យគេយកប្រាក់កម្រៃ ☐នៅធ្វើការផ្ទះ<br>☐ដើរលេងជាមួយមិត្តភក្តិ ☐ផ្សេងៗ( សូមបញ្ជាក់) :____________<br><u>សមាជិកទី៤:</u>☐ធ្វើស្រែចំការ ☐រកត្រី ☐ធ្វើការឱ្យគេយកប្រាក់កម្រៃ ☐នៅធ្វើការផ្ទះ<br>☐ដើរលេងជាមួយមិត្តភក្តិ ☐ផ្សេងៗ( សូមបញ្ជាក់) :____________<br><u>សមាជិកទី៥:</u>☐ធ្វើស្រែចំការ ☐រកត្រី ☐ធ្វើការឱ្យគេយកប្រាក់កម្រៃ ☐នៅធ្វើការផ្ទះ<br>☐ដើរលេងជាមួយមិត្តភក្តិ ☐ផ្សេងៗ( សូមបញ្ជាក់) :____________<br><u>សមាជិកទី៦:</u>☐ធ្វើស្រែចំការ ☐រកត្រី ☐ធ្វើការឱ្យគេយកប្រាក់កម្រៃ ☐នៅធ្វើការផ្ទះ<br>☐ដើរលេងជាមួយមិត្តភក្តិ ☐ផ្សេងៗ( សូមបញ្ជាក់) :____________<br><u>សមាជិកទី៧:</u> ☐ធ្វើស្រែចំការ ☐រកត្រី ☐ធ្វើការឱ្យគេយកប្រាក់កម្រៃ ☐នៅធ្វើការផ្ទះ<br>☐ដើរលេងជាមួយមិត្តភក្តិ ☐ផ្សេងៗ( សូមបញ្ជាក់) :____________<br><u>សមាជិកទី៨:</u>☐ធ្វើស្រែចំការ ☐រកត្រី ☐ធ្វើការឱ្យគេយកប្រាក់កម្រៃ ☐នៅធ្វើការផ្ទះ<br>☐ដើរលេងជាមួយមិត្តភក្តិ ☐ផ្សេងៗ( សូមបញ្ជាក់) :____________<br><u>សមាជិកទី៩:</u> ☐ធ្វើស្រែចំការ ☐រកត្រី ☐ធ្វើការឱ្យគេយកប្រាក់កម្រៃ ☐នៅធ្វើការផ្ទះ<br>☐ដើរលេងជាមួយមិត្តភក្តិ ☐ផ្សេងៗ( សូមបញ្ជាក់) :____________<br><u>សមាជិកទី១០:</u>☐ធ្វើស្រែចំការ ☐រកត្រី ☐ធ្វើការឱ្យគេយកប្រាក់កម្រៃ ☐នៅធ្វើការផ្ទះ<br>☐ដើរលេងជាមួយមិត្តភក្តិ ☐ផ្សេងៗ( សូមបញ្ជាក់) :____________<br>យោបល់ ឬសំណូមពររបស់អ្នកឆ្លើយ:<br>________________________________________ | 10 9<br>8 7 6<br>5 4 3<br>2 1 0 |

| | | |
|---|---|---|
| **5** | តើអ្នកគិតថា យុវជន និងមនុស្សវ័យក្មេងមានចិត្តចង់ជួយធ្វើការងារអភិវឌ្ឍឬទេ? បើពួកគេចង់ សួរថា តើការងារអ្វី ហើយធ្វើដូចម្តេច?<br>សមាជិកទី១: ☐បាទ /ចាស ____________________________ ☐ទេ<br>សមាជិកទី២: ☐បាទ /ចាស ____________________________ ☐ ទេ<br>សមាជិកទី៣: ☐បាទ /ចាស ____________________________ ☐ទេ<br>សមាជិកទី៤:☐បាទ /ចាស ____________________________ ☐ទេ<br>សមាជិកទី៥: ☐បាទ /ចាស ________ ____________________ ☐ ទេ<br>សមាជិកទី៦: ☐បាទ /ចាស ____________________________ ☐ទេ<br>សមាជិកទី៧: ☐បាទ /ចាស ____________________________ ☐ ទេ<br>សមាជិកទី៩: ☐បាទ /ចាស ____________________________ ☐ ទេ<br>សមាជិកទី១០: ☐បាទ /ចាស ____________________________☐ទេ<br>យោបល់ ឬសំណូមពររបស់អ្នកឆ្លើយ:<br>________________________________________ | 10 9<br>8 7 6<br>5 4 3<br>2 1 0 |
| **6** | កម្មវិធីអេស្កាប់ និងអង្គការដៃគូ មានផែនការបង្កើតក្រុមយុវវ័យនៅតាមភូមិ ដើម្បីឱ្យពួកគេ យកចំណេះដឹងរបស់គេ ជួយដល់កុមារនៅសហគមន៍។ បើមានការជួយគាំទ្រពីពួកយើងទាំង អស់គ្នា តើអ្នកគិតថា ពួកគេអាចធ្វើបានឬទេ?<br>សមាជិកទី១: ☐បាទ /ចាស ____________________________ ☐ទេ<br>សមាជិកទី២: ☐បាទ /ចាស ____________________________ ☐ ទេ<br>សមាជិកទី៣: ☐បាទ /ចាស ____________________________ ☐ទេ<br>សមាជិកទី៤:☐បាទ /ចាស ____________________________ ☐ទេ<br>សមាជិកទី៥: ☐បាទ /ចាស ________ ____________________ ☐ ទេ<br>សមាជិកទី៦: ☐បាទ /ចាស ____________________________ ☐ទេ<br>សមាជិកទី៧: ☐បាទ /ចាស ____________________________ ☐ ទេ<br>សមាជិកទី៨: ☐បាទ /ចាស ____________________________ ☐ទេ<br>សមាជិកទី៧: ☐បាទ /ចាស ____________________________ ☐ ទេ<br>សមាជិកទី៨: ☐បាទ /ចាស ____________________________ ☐ទេ<br>យោបល់ ឬសំណូមពររបស់អ្នកឆ្លើយ: ____________________________ | 10 9<br>8 7 6<br>5 4 3<br>2 1 0 |
| **ពិន្ទុសរុប:** | | |

**ឧបសម្ព័ន្ធទី៣:**

## ទស្សនកម្រងទិសអំពីការបង្កើតក្រុមយុវវ័យ
## ជាមួយយុវវ័យនៅតាមភូមិ

**ការចាប់ផ្តើម** **ការចុះឈ្មោះក្នុងបញ្ជីវត្តមាន**

ផ្តល់បញ្ជីវត្តមានឱ្យសិក្ខាកាមបំពេញឈ្មោះ និងចុះហត្ថលេខា ដោយបន្តបញ្ជីនេះពីម្នាក់ទៅម្នាក់ រហូតដល់គ្រប់គ្នា ហើយប្រគល់ឱ្យអ្នកសម្របសម្រួលវិញ។

**ការស្វាគមន៍** (យ៉ាងច្រើនបំផុត៥នាទី)

នៅពេលសិក្ខាកាម បានជួបជុំគ្នាអស់ហើយ នាំសិក្ខាកាមរៀបកន្លែងអង្គុយជារង្វង់។ អ្នកសម្របសម្រួលណែនាំខ្លួនដោយប្រាប់ឈ្មោះ មុខងារ និងទីកន្លែងធ្វើការ ហើយសំដែងការស្វាគមន៍ចំពោះការចូលរួមរបស់សិក្ខាកាម។

**ការណែនាំខ្លួនរបស់សិក្ខាកាម** (១០នាទី)

សិក្ខាកាមណែនាំខ្លួនដោយប្រាប់ឈ្មោះ និងភូមិដែលខ្លួនរស់នៅ ។

**គោលបំណងសិក្ខាសាលា**((៥នាទី)

ពន្យល់ដល់សិក្ខាកាមយ៉ាងសង្ខេប អំពីគោលបំណងនៃការជួបជុំគ្នាក្នុងថ្ងៃនេះ ដែលក្នុងនោះរួមមាន:

- ដើម្បីបង្កើតវេទិកាមួយ ដែលបង្កឱ្យយុវវ័យបានជួបជុំគ្នា ពិនិត្យលទ្ធភាពក្នុងការរៀបចំក្រុមយុវវ័យនៅតាមភូមិ។
- ដើម្បីពិភាក្សាអំពីការទទួលខុសត្រូវនិងការងាររបស់ក្រុមយុវវ័យនៅតាមភូមិ។
- ដេម្បីបង្កើតភាពសប្បាយរីករាយ ក្នុងការជួបជុំគ្នាថ្ងៃនេះ។

និយាយអំពីសកម្មភាពដែលត្រូវធ្វើនៅក្នុងសិក្ខាសាលានេះ។ ពន្យល់អំពីការងាររដ្ឋបាល និងការផ្គត់ ផ្គង់ ហើយបន្តការពិភាក្សាលើបទបញ្ជាផ្ទៃក្នុង សម្រាប់សិក្ខាសាលា ដើម្បីធ្វើឱ្យសិក្ខាសាលានេះមានដំណើរការល្អ រួមមានដូចជាការបញ្ចេញយោបល់ឱ្យបានច្រើន ការ គោរពយោបល់អ្នកដទៃ មិនប្រកែកយកឈ្នះចាញ់ តែរើកញែករកហេតុផល ដើម្បីសម្រេចគោលដៅដែលចង់បាន។ល។

**ការរៀបចំក្រុម** (៥នាទី)

ឯកភាពជាមួយសិក្ខាកាម ក្នុងការរៀបចំការអង្គុយជាក្រុម។ ប្រាប់ពួកគេថា គេត្រូវអង្គុយជាក្រុមដែលមានគ្នា ៤-៥នាក់ ហើយប្រហែលជាគេអាចរៀបចំក្រុមដោយខ្លួនឯង គឺធ្វើយ៉ាង ណាឱ្យគេមានអារម្មណ៍កក់ក្តៅ ក្នុងការចូលរួមមានយោបល់ក្នុងក្រុម។

**សេចក្តីសង្ខេប** ***តើអេស្កាប់ជាអ្វី ហើយអេស្កាប់ធ្វើអ្វីខ្លះ?*** (១០នាទី)

**អំពីកម្មវិធី** ល្បែង៖ "រកអ្នកដែល....."

**អេស្កាប់** ចែកប័ណ្ណ 'រកអ្នកដែល' ឱ្យសិក្ខាកាមម្នាក់មួយសន្លឹក។ ឱ្យសិក្ខាកាមងើបឈរ ហើយដើររកគ្នានៅក្នុងបន្ទប់រៀន ជជែកគ្នា ដោយសួរសំណួរពីម្នាក់ទៅម្នាក់ទៀត ដោយសួរសំណួរមួយសម្រាប់មនុស្សម្នាក់ រហូតដល់អស់សំណួរ។ នៅពេលសួរសំណួរហើយ ត្រូវសរសេរឈ្មោះអ្នកដែលឆ្លើយឯកភាពលើសំណួរនោះ នៅក្នុងជួរខាងស្តាំ។

| | រកអ្នកដែល៖ | ឈ្មោះ |
|---|---|---|
| 1 | ធ្លាប់បានឮអំពីកម្មវិធីអេស្កាប់។ | |
| 2 | គិតថាអេស្កាប់ជាកម្មវិធីអប់រំ សម្រាប់កុមារដែលរស់នៅតំបន់ជនបទ និងដាច់ស្រយ៉ាល។ | |
| 3 | យល់ថាអេស្កាប់ គួរតែគួរតែធ្វើការជាមួយយុវជនក្រៅសាលាដែរ ដើម្បីឱ្យគេរួមចំនែកជួយក្នុងការងារអភិវឌ្ឍ។ | |
| 4 | យុវជនក្នុងភូមិយើង គួរតែរកមធ្យោបាយ ជួយលើកទឹកចិត្តកុមារឱ្យខំប្រឹងរៀន។ | |
| 5 | យល់ថាបើកុមារី និងកុមារានឹងរៀនពូកែដូចគ្នា បើពួកគេទទួលបានការគាំទ្រស្មើគ្នា។ | |

លំហាត់នេះ ជួយអ្នកសម្របសម្រួលឱ្យបានដឹងពីកម្រិតយល់ដឹងរបស់សិក្ខាកាមអំពីកម្មវិធីអេស្កាប់។ ពន្យល់បន្ថែមអំពីចំនុចសំខាន់ៗរបស់កម្មវិធីអេស្កាប់ ដូចជាគោលបំណងកម្មវិធី វិសាលភាពកម្មវិធី ក្រុមគោលដៅ និងរបៀបរបបការងាររបេស់កម្មវិធី ។ ផ្តល់ឱកាសឱ្យសិក្ខាកាមសួរសំណួរ ហើយអ្នកសម្របសម្រួលបកស្រាយចម្ងល់ បើមាន។

**ជំហានក្នុង** ***តើក្រុមយុវវ័យជាអ្វី?*** (១០នាទី) សរសេរ

**ការបង្កើត** សរសេរពាក្យ " ក្រុមយុវវ័យ" នៅលើក្តារខៀន ឬលើផ្ទាំងក្រដាស ហើយសួរសិក្ខាកាមថា

**ក្រុមយុវវ័យ តាមភូមិ**

តើពាក្យនេះមានន័យដូចម្ដេចចំពោះពួកគេ។ ឱ្យសិក្ខាកាមគិតថា តើពួកគេជាយុវជនតំណាងឱ្យក្រុម ណា (ពួកគេអាចក្រុមមួយដែលតំណាងឱ្យក្រុមយុវវ័យ នៅក្នុងភូមិណាមួយ ឬក្រុមយុវវ័យណាមួយ ដូចជាក្រុមយុវវ័យជនជាតិ យុវវ័យចំណាកស្រុក យុវវ័យពិការ យុវវ័យក្នុងសាលា សមាគមយុវជនជាដើម។

អ្នកសម្របសម្រួលកត់ត្រានិយមន័យដែលសិក្ខាកាមបានលើកឡើង។ បន្ទាប់មកពន្យល់គោលគំនិតអំពីក្រុមយុវវ័យនៅតាមភូមិ ដោយនិយាយថា ពេលខ្លះមនុស្សវ័យក្មេងចង់យកពេលទំនេររបស់ពួកគេ ដើម្បីជួយដល់សកម្មភាពអភិវឌ្ឍ។ ប៉ុន្តែ ពួកគេពុំដឹងថាគួរធ្វើអ្វី ហើយមិនដឹងថាធ្វើតែម្នាក់ឯងដូចម្ដេចកើត។ ដូច្នេះ ការបង្កើតជាក្រុមនិងការផ្ដល់ចំណេះដឹងនិងបំណិនដល់យុវវ័យ អាចធ្វើឱ្យពួកគេមានសមត្ថភាពធ្វើការជាមួយអ្នកពាក់ព័ន្ធនានា ហើយអាចដោះស្រាយបញ្ហាផ្សេងៗ ដើម្បីនាំមកនូវការផ្លាស់ប្ដូរវិជ្ជមាន។អេស្កាប់កំពុងគិតរៀបចំបង្កើត ឬពង្រឹងបណ្ដាញយុវវ័យនៅក្នុងភូមិ ដែលអាចឱ្យយុវវ័យចូលរួមជួយដល់កុមារក្នុងការដោះស្រាយកង្វល់របស់ពួកគេ។ ម្យ៉ាងទៀតការចូលរួមនេះ ធ្វើឱ្យយុវវ័យអាចអភិវឌ្ឍខ្លួន និងចេះដោះស្រាយបញ្ហា ដោយខ្លួនឯងបាន។ *ក្រុមយុវវ័យនឹងអនុវត្តសកម្មភាពនៅក្រៅសាលា ប៉ុន្តែជាមួយនិងដើម្បីកុមារក្នុងសាលា*។ អ្នកពាក់ព័ន្ធទាំងអស់ត្រូវសហការគ្នាក្នុងការផ្ដល់ការបន្តគាំទ្រដល់ក្រុមយុវវ័យក្នុងដំណើរការការងាររបស់ពួកគេ បន្ទាប់មក គូសរចនាសម្ព័ន្ធនៅលើក្ដារខៀន។ ទុកពេលឱ្យសិក្ខាកាមគិត ពិភាក្សាគ្នាជាដៃគូ។ លើកទឹកចិត្តពួកគេឱ្យសួរសំណួរទាក់ទងនឹងរចនាសម្ព័ន្ធ ដែលបង្ហាញនេះ។

**ហេតុអ្វីចាំបាច់ មានការចូលរួម ពីយុវវ័យ?**

***មូលហេតុ និងផលប្រយោជន៍ដែលទទួលបានពីការចូលរួមរបស់យុវវ័យ***

សួរសំណួរថា: តើ "ការចូលរួមរបស់យុវវ័យ" មានន័យដូចម្ដេច?

ចម្លើយរំពឹងទុកអាចរួមមាន: "ការចូលរួមរបស់យុវវ័យ" សំដៅលើការស្វាគមន៍យុវវ័យឱ្យចូលរួមក្នុងសកម្មភាសពអភិវឌ្ឍនានា។ បញ្ញត្តិនៃ "ការចូលរួមរបស់យុវវ័យ"គឺជាការចូលរួមដ៏មានន័យ ក្នុងសកម្មភាពណាមួយ ដើម្បីផលប្រយោជន៍រួម មិនមែនដើម្បីខ្លួនឯង។ "ការចូលរួមរបស់យុវវ័យ " ក៏សំដៅផងដែរទៅលើលំនាំនៃការរីកចម្រើនឥតឈប់ឈរ ដែលជួយឱ្យបុគ្គលម្នាក់ៗឈានទៅសម្រេចសេចក្ដីត្រូវការរបស់ខ្លួនបាន។

ពន្យល់សិក្ខាកាមថា ហេតុផលនៃការចូលរួមរបស់យុវវ័យ ក្នុងការចាត់ចែងនិងធ្វើការសម្រេចចិត្តដើម្បីរួមចំណែកលើកស្ទួយនិងអភិវឌ្ឍសហគមន៍ តែងតែចាប់ផ្ដើមពីការផ្ដោត

ទៅលើសិទ្ធិមនុស្ស និងស្មារតីនិងការទទួលខុសត្រូវជាពលរដ្ឋរបស់មនុស្សគ្រប់រូប រួមទាំងយុជន/យុវតីផងដែរ ។

បែងចែកសិក្ខាកាមជាក្រុមដែលមានគ្នា៥-៦នាក់។ បិទតារាងដែលបង្ហាញ ខាងក្រោមនៅលើជញ្ជាំង ហើយឱ្យក្រុមពិភាក្សាទៅលើផលប្រយោជន៍ដែលអ្នកពាក់ព័ន្ធ( យុវវ័យ អង្គការ និងសហគមន៍) បានទទួលពីការចូលរួមរបស់យុវវ័យ។

| **មូលហេតុនិងផលប្រយោជន៍ដែលទទួលបានពីការចូលរួមរបស់យុវវ័យ** | | |
|---|---|---|
| **សម្រាប់យុវវ័យខ្លួនឯង** | **សម្រាប់អង្គការ** | **សម្រាប់សហគមន៍** |
| | | |

ក្រុមនីមួយៗកត់ត្រាលទ្ធផលនៃការពិភាក្សាលើផ្ទាំងក្រដាសធំ។ ពេលពិភាក្សាចប់ បិទផ្ទាំងក្រដាសនោះនៅលើជញ្ជាំង។ ឱ្យសិក្ខាកាមដើរមើលលទ្ធផលការងារ របស់ក្រុមដទៃប្រមាណ ៥ នាទី រួចហើយធ្វើការបូកសរុប ដោយបង្ហាញតារាងខាងក្រោម:

| **មូលហេតុនិងផលប្រយោជន៍ដែលទទួលបានពីការចូលរួមរបស់យុវវ័យ** | | |
|---|---|---|
| **សម្រាប់យុវវ័យខ្លួនឯង** | **សម្រាប់អង្គការ** | **សម្រាប់សហគមន៍** |
| <u>អភិវឌ្ឍបំណិនដើម្បីក្លាយជាមនុស្សពេញវ័យដែលមានសមត្ថភាព:</u> យុវ័យអាចរៀន និងអភិវឌ្ឍបំណិនផ្សេងៗ ដូចជាការសម្របសម្រួល ការធ្វើផែនការ ការចាត់ចែង ការដឹកនាំ ។ល។ <u>បង្កើតទំនាក់ទំនងក្នុងសង្គម:</u> យុវ័យអាចជួបជាមួយកុមារ និងមនុស្សចាស់ ផ្សារភ្ជាប់ទំនាក់ទំនងនឹងគ្នា។ <u>កាត់បន្ថយគ្រោះថ្នាក់ ផ្សេងៗ ទាក់ទងនឹងការប្រព្រឹត្តផ្តេសផ្តាស ឬការចំអកឡកឡឺយពីមនុស្សចាស់:</u> កាត់បន្ថយការផឹកស្រា ការជក់បារី ការប្រើគ្រឿងញៀន អំពើហឹង្សា ឬការប្រព្រឹត្តបទល្មើសផ្សេងៗមាន | <u>ការធ្វើការសម្រេចចិត្តបានល្អជាងមុន:</u> អង្គការអាចធ្វើការសម្រេចចិត្តបានល្អជាងមុន ទៅលើបញ្ហាទាក់ទងនឹងយុវវ័យ ដោយសារក្រុមយុវវ័យផ្តល់នូវគំនិតថ្មីៗ។ <u>យុទ្ធវិធីនិងការអនុវត្តល្អជាងមុន:</u> អង្គការអាចបង្កើត និងអនុវត្តការងារតាមយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពជាងមុន។ | សង្គមដែលមានការចូលរួម: យុវវ័យត្រូវបានផ្តល់ចំណេះដឹងដើម្បីឱ្យក្លាយជាសមាជិកដ៏សកម្មនៅក្នុងសហគមន៍ ដែលកុមារអាចរៀនសូត្រ និងទទួលការគាំទ្រពីពួកគេបាន។ កាត់បន្ថយទំនាស់និងការមិនទុកចិត្តគ្នា : យុវវ័យចំនាយពេលវេលារបស់ពួកគេដើម្បីធ្វើការងារអភិវឌ្ឍ និងជំនះលើទស្សនៈអវិជ្ជមានចំពោះតួនាទីបុរស/ស្ត្រី |

| | | |
|---|---|---|
| ចំនុចល្អៗជាច្រើនទៀត ដូចជាមានមោទនភាពចំពោះខ្លួនឯង ដោយមានការតាំងចិត្តជួយដល់អ្នកដទៃជាដើម ។ល ។ | | |

**ការទទួលខុសត្រូវរបស់ក្រុមយុវវ័យតាមភូមិ**

***តើការទទួលខុសត្រូវមានន័យដូចម្តេច?***



បំផុសសំណួរក្នុងក្រុមធំ (សរសេរសំណួរនៅលើក្តារខៀន)

១-កាលនៅពីក្មេង (កុមារភាព) តើអ្នកមានការទទួលខុសត្រូវអ្វីខ្លះ?

២-តើអ្នករៀនសូត្របានអ្វីខ្លះ ពីការទទួលខុសត្រូវទាំងនោះ?

៣-តើនឹងមានអ្វីកើតឡើង បើមនុស្សម្នាក់ៗមិនបំពេញតួនាទី ឬពុំមានការទទួលខុសត្រូវអ្វីសោះ?

**ប៉ុស្ទ័រស្តីអំពីការទទួលខុសត្រូវ**

1- ចម្លើយផ្អែកតាមការបទពិសោធន៍របស់សិក្ខាកាម

2- ការទទួលខុសត្រូវ គឺមិនមែនអ្វីដែលតម្រូវឬបង្ខំយើងនោះទេ ប៉ុន្តែវាជាអ្វីដែលធ្វើឱ្យយើង សម្រេចគោលបំណងដែលយើងចង់បាន ។

- ការទទួលខុសត្រូវ គឺការប្រើប្រាស់ធនធាន ដើម្បីបង្កើតឱ្យមានការផ្លស់ប្តូរជាវិជ្ជមាន- ហើយការផ្លាស់ប្តូរនោះ អាចជាប្រយោជន៍ ដល់សហគមន៍ -
- មនុស្ស (យើងទាំងអស់គ្នា) ជាអ្នកធ្វើឱ្យមានភាពខុសគ្នា!

3- ការទទួលខុសត្រូវ ទាមទារឱ្យមានការគោរពគ្នា ក្នុងនាមជាមនុស្សជាតិដូចគ្នា

4- មនុស្សដែលមានការទទួលខុសត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន គឺធ្វើអ្វីមួយដោយមានគោលបំណងច្បាស់លាស់ ប្រកនបដោយភាពត្រឹមត្រូវនឹងភាពសុចរិត ។

ឧទាហរណ៏ដែលបង្ហាញពីលទ្ធផលនៃការទទួលខុសត្រូវ របស់មនុស្សនៅក្នុងភូមិ មួយធ្វើឱ្យមានការផាស់ប្តូរ ដូចជា : បរិស្ថានក្នុងភូមិស្អាតជាងមុន ចំនួនអក្ខរជននៅក្នុងភូមិបានកើនឡើង សាលារៀនស្អាត កុមារចូលរៀនច្រើនជាងមុន មានសន្តិសុខ និងសណ្តាប់ធ្នាប់ គ្មានអំពើហឹង្សា ការប្រើគ្រឿងញៀន ។ល ។

**ភារកិច្ច និងការទទួលខុសត្រូវ** ឱ្យសិក្ខាកាមធ្វើការជាក្រុម ពិចារណាទៅលើប៉ុស្ទ័រខាងលើ ហើយពិភាក្សាគ្នារកគម្រោង ឬសកម្មភាពដែលពួកគេអាចទទួលខុសត្រូវបាន ។ការទទួលខុសត្រូវនោះ អាចជាការងារដែល



**របស់ក្រុមយុវវ័យ** ម្នាក់ៗអាចធ្វើបាន ឬអាចធ្វើជាក្រុម ដូចជាការផ្តល់សេវា ដល់កុមារនៅក្នុងភូមិជាដើម ។

**នៅតាមភូមិ** ឱ្យពួកគេថានិយាយពីបទពិសោធន៍ផ្ទាល់ខ្លួន ដោយគិតថាការទទួលខុសត្រូវអ្វីខ្លះ ដែលគួរធ្វើ ដើម្បីភូមិដែលគេរស់នៅ ។

ក្រុមនីមួយៗឡើងបង្ហាញ ។

ប្រៀបធៀបគំនិតសិក្ខាកាមជាមួយគំនិតត្រៀមទុកនៅលើប៉ុស្ត័រខាងក្រោម ហើយទុកពេលឱ្យសិក្ខាកាមសួរសំណួរ ។

បូកសរុប ដោយធ្វើឱ្យមានការឯកភាពកើការទទួលខុសត្រូវរបស់យុវវ័យ ដោយពន្យល់ថាអ្វីដែលគេបានគិតក្នុងក្រុម នឹងត្រូវយកមកពិភាក្សា ជាមួយក្រុមយុវវ័យបន្ទាប់ពីក្រុមនេះត្រូវបានបង្កើតឡើង ដើម្បីរៀបចំផែនការលំអិតសម្រាប់អនុវត្ត ។

(តួនាទីនិងភារកិច្ច សូមមើលឧបសម្ព័ន្ធទី៤)

**ការដាក់ពាក្យសុំចូលជាសមាជិកក្រុមយុវវ័យតាមភូមិ** ពន្យល់ថា ហេតុអ្វីចាំបាច់ដាក់ពាក្យ? - ការបង្កើតក្រុមយុវវ័យតាមភូមិ គឺធ្វើដោយផ្អែកទៅតាមគោលការស្ម័គ្រចិត្ត ដើម្បីឱ្យមានការចូលរួមពិតប្រាកដ (សមាជិកដែលមានទំនុកចិត្ត ឆន្ទៈនិងការតាំងចិត្ត) ។

ចែកពាក្យសុំ (ឧបសម្ព័ន្ធទី៤) ដល់សិក្ខាកាមម្នាក់ៗ ។

ពិនិត្យពាក្យសុំនេះឡើងវិញ ដោយអានប្រយោគមួយឃ្លាម្តងៗ ជាមួយសិក្ខាកាម ។ ទុកពេលឱ្យពួកគេគិត ហើយបើគេយល់ថាគេពិតជាចាប់អារម្មណ៍ចង់ដាក់ពាក្យ គេត្រូវបំពេញទម្រង់ដាក់ក្នុងស្រោមសំបុត្រ ហើយប្រគល់ឱ្យក្រុមគាំទ្រ នៅសប្តាហ៍បន្ទាប់ ។ គួរកត់សំគាល់ថា យុវវជនដែលដាក់ពាក្យទាំងអស់ ពុំមែនសុទ្ធតែត្រូវបានទទួលឱ្យចូល ក្នុងក្រុមយុវវ័យទាំងអស់នោះទេ ។

ចុងក្រោយបង្អស់ ទុកពេលឱ្យសិក្ខាកាមសួរសំណួរ ។ បកស្រាយសំណួរ បើមានចង្ងល់ ។

**ឧបសម្ព័ន្ធទី៤:**<u>**រចនាសម្ព័ន្ធក្រុមយុវវ័យនៅតាមមូលដ្ឋាន**</u>




អនុប្រធានអាចមានលើសពីពីរនាក់ ទៅតាមទំហំនៃក្រុមដែលបង្កើត។ ឧទាហរណ៍ បើក្រុមមួយមានសមាជិក ២០នាក់ អនុប្រធានអាចមានចាប់ពី៣នាក់ឡើងទៅ ប្រសិនបើមានការចាំបាច់។

<u>**តួនាទី និងភារកិច្ចរបស់ក្រុមយុវវ័យ:**</u>

១. ប្រជុំជាមួយសមាជិកក្នុងក្រុម (និងជាមួយកុមារ) ដើម្បីពិភាក្សាបញ្ហានិងធ្វើផែនការ។

២. ផ្តល់ការណែនាំ និងលើកកំពស់ការយល់ដឹង ទាក់ទងនឹងការងារអប់រំ សង្គម និងសុខភាព (ឧ. អំពើហិង្សាក្នុងគ្រួសារ អំពើជួញដូរកុមារ យេនឌ័រនិងភាពប្លែកពីគ្នា តួនាទីនៃវប្បធម៌នៅក្នុងការអប់រំ ការចៀសវាងការរាលដាលនៃជម្ងឺអេដស៍ និងគ្រឿងញៀនជាដើម។ល។)

៣. ជួយកុមារឱ្យពួកគេបានដឹងថា:

- ពួកគេត្រូវជួយសំអាតទីធ្លាសាលាដោយរើសសម្រាមដាក់ក្នុងធុងសម្រាម។
- ពួកគេត្រូវដាក់ផែនការ ដាំដើមឈើ នៅពេលណាមួយ និងថែទាំដើមឈើ។
- ពួកគេត្រូវពិនិត្យមើលបរិស្ថានសាលារៀន និងលំនៅដ្ឋាន។

៤. ចាត់ចែងក្លឹបសិក្សា ក្រៅម៉ោងរៀន។

៥. ជួយសិស្សដែលត្រូវឪពុកម្តាយឱ្យជួយការផ្ទះច្រើន តាមរយៈការជួយបង្រៀនបន្ថែមនៅពេលទំនេរ។

៦. រៀបចំសកម្មភាពកំសាន្តផ្សេងៗជាមួយកុមារ និងដើម្បីកុមារ ដូចជាសកម្មភាសពកីឡា សិល្បៈ និងសកម្មភាពស្រាវជ្រាវផ្សេងៗ ដើម្បីស្វែងយល់ពីសហគមន៍។

៧. រៀបចំនិងចាត់ចែងទិវាយុវវ័យ {Youth Activity Day (YAD)} ដោយឱ្យកុមារចូលរួមបង្ហាញនូវអ្វីដែលពួកគេបានធ្វើ ឬបានរៀនពីសកម្មភាពដែលពួកគេបានចូលរួមកន្លងមក។

៨. ចូលរួមក្នុងសកម្មភាពបង្រៀនសិស្សរៀនយឺត ដោយសហការជាមួយគ្រូបង្រៀន។

៩. ចុះតាមផ្ទះសិស្សដែលអវត្តមាន និងសិស្សបោះបង់ ដោយសហការជាមួយគ្រូបន្ទុកថ្នាក់។

១០. សរសេររបាយការណ៍ឬកត់ត្រាករណីសិក្សា ឬលទ្ធផលល្អៗ ពីសកម្មភាពការងាររបស់ពួកគេ។

**ឧបសម្ព័ន្ធទី៥:**

# Educational Support for Children in Underserved Populations

## កម្រងសំណួរសម្រាប់ជ្រើសរើសក្រុមយុវជនវ័យនៅតាមភូមិ

| | | | |
|---|---|---|---|
| ខេត្ត: ____________ | ស្រុក: ________________ | ឃុំ: _______________ | ភូមិ: _____________________ |
| ឈ្មោះ: ____________________________________ | | ភេទ: ______________ | អាយុ: ___________________ |
| □ កំពុងរៀននៅអនុវិទ្យាល័យ | □ ឈប់រៀនហើយ | មកពីសហគមន៍ជនជាតិ: ____________________ | |

**ការណែនាំ:** សូមអានសំណួរនីមួយៗ ដែលមាននៅខាងក្រោម ហើយឆ្លើយដោយស្មោះត្រង់ ✓ ដោយគូសក្នុងប្រអប់ដែលអ្នកយល់ថាសមស្រប ។ ទម្រង់នេះ នឹងត្រូវរក្សាជាការសម្ងាត់ ។

| **ផ្នែកទី១: ប្រវត្តិទូទៅ** | | |
|---|---|---|
| 1 | តើប្អូនរៀនដល់ថ្នាក់ណាដែរ? □ ថ្ន.ទី១ □ ថ្ន.ទី២ □ ថ្ន.ទី៣ □ ថ្ន.ទី៤ □ ថ្ន.ទី៥ □ ថ្ន.ទី៦<br>□ ថ្ន.ទី៧ □ ថ្ន.ទី៨ □ ថ្ន.ទី៩ □ ថ្ន.ទី១០ □ ថ្ន.ទី១១ □ ថ្ន.ទី១២ | 1 2 3 4 5<br>6 7 8 9<br>10 11 12 |
| 2 | បើឈប់រៀនហើយ តើឈប់នៅឆ្នាំណា ហើយដោយសារមូលហេតុអ្វី? នៅឆ្នាំ .......................<br>□ ខ្វះថវិកា ដើម្បីទិញសម្ភារសិក្សា<br>□ ត្រូវទៅធ្វើការរកប្រាក់ជួយដល់គ្រួសារ<br>□ ប្រលងធ្លាក់<br>□ ចិត្តចង់ឈប់រៀន ដោយខ្លួនឯង<br>□ ផ្សេងៗ( សូមបញ្ជាក់..........................................................................................) | 1 0 |
| 3 | តើប្អូនធ្លាប់បានចូលរួមក្នុងសកម្មភាពអភិវឌ្ឍនៅក្នុងភូមិឬសលារៀននៅក្នុងភូមិរបស់ប្អូនឬទេ?<br>□ ធ្លាប់ □ មិនធ្លាប់<br>□ បើធ្លាប់ តើបានចូលរួមក្នុងសកម្មភាពអ្វីខ្លះ?<br>□ ចូលរួមក្នុងការធ្វើផែនការឃុំ<br>□ ចូលរួមក្នុងការប្រជុំនៅតាមភូមិ ជំនួសឪពុកម្តាយ<br>□ ចូលរួមក្នុងការដាំដើមឈើ /ជួសជុលផ្លូវឬស្ពាន នៅក្នុងភូមិ<br>□ ចូលរួមផ្សព្វផ្សាយពីបញ្ហាសុខភាព ជាមួយក្រុមផ្សព្វផ្សាយ<br>□ ធ្លាប់ធ្វើជាអ្នកស្ម័គ្រចិត្តជាមួយអង្គការ ( បញ្ជាក់អង្គការតឈ្មោះអ្វី :......................................)<br>□ ផ្សេងៗ( សូមបញ្ជាក់..........................................................................................) | 0 1 |
| 4 | តើប្អូនធ្លាប់បានចូលរួមក្នុងសមាគម ឬគណៈកម្មការណាដែរឬទេ? □ ធ្លាប់ □ មិនធ្លាប់<br>បើធ្លាប់ សូមបញ្ជាក់: | 0 1 |

| | | |
|---|---|---|
| | □ សមាគមយុវជន<br>□ សមាគមសាសនា<br>□ ផ្សេងៗ(សូមបញ្ជាក់.........................................................................................) | |
| | **ផ្នែកទី២: កម្រិតនៃការចាប់អារម្មណ៍** | |
| 5 | ក្មេងៗដែលជាជនជាតិផ្សេងគ្នា មិនចង់ធ្វើការជាមួយគ្នាទេ។ បើសិនជាដាក់ពួកគេ ឱ្យនៅក្នុងក្រុមជាមួយគ្នា នោះទំនាស់អាចនឹងកើតឡើង។<br>□ ឯកភាពទាំងស្រុង □ ឯកភាព □ មិនដឹង □ មិនឯកភាព □ មិនឯកភាពទាល់តែសោះ | 1 2 3<br>4 5 |
| 6 | ពួកក្មេងៗពុំដែលមានយោបល់អ្វីទេ ហើយបើមានយោបល់វិញ យោបល់នោះក៏ឥតប្រយោជន៍ដែរ។<br>□ ឯកភាពទាំងស្រុង □ ឯកភាព □ មិនដឹង □ មិនឯកភាព □ មិនឯកភាពទាល់តែសោះ | 1 2 3<br>4 5 |
| 7 | វាធ្វើឱ្យខ្ញុំហត់នឿយ ហើយគួរឱ្យធុញទ្រាន់ បើធ្វើការជាមួយក្មេងដែលឆុងឆាំង និងឆាឆៅរំខានគេឯង។<br>□ ឯកភាពទាំងស្រុង □ ឯកភាព □ មិនដឹង □ មិនឯកភាព □ មិនឯកភាពទាល់តែសោះ | 1 2 3<br>4 5 |
| 8 | ការងាររបស់ខ្ញុំគឺដាស់តឿនក្មេងៗឱ្យចូលរួមក្នុងសកម្មភាពឬការងារផ្សេងៗ។ ក្មេងម្នាក់និយាយថាគេធុញ ហើយមិនចង់ចូលរួមក្នុងសកម្មភាពនោះទេ ។ ករណីបែបនេះ ខ្ញុំនឹង:<br>□ សួរគេថាហេតុអ្វី?<br>□ សួរគេថាតើគេចង់ធ្វើអ្វីវិញ?<br>□ ប្រាប់គេថា មិនចាំបាច់ធ្វើអ្វីទេ គ្រាន់តែនៅអង្គុយជាមួយគេឯងទីនេះទៅបានហើយ<br>□ ប្រាប់គេឱ្យចេញទៅ | 1<br><br>0 |
| 8 | ក្រុមយុវវ័យចង់ជួបជុំគ្នា ដោយការប្រជុំជាផ្លូវការផង និងមិនផ្លូវការផង។ ដូច្នេះ ការធ្វើដំណើរទៅមកដើម្បីជួបជុំគ្នានេះ គឺជាកង្វល់ដ៏ធំ។<br>□ ឯកភាពទាំងស្រុង □ ឯកភាព □ មិនដឹង □ មិនឯកភាព □ មិនឯកភាពទាល់តែសោះ | 1 2 3<br>4 5 |
| 9 | បញ្ហាជាច្រើនអាចដោះស្រាយបាន ដោយមិនចាំបាច់តាមរយៈការប្រជុំ។ ការជួបជជែកគ្នាក្រៅផ្លូវការ ដូចជាជាមួយកុមារ និងឪពុកម្តាយកុមារ ធ្វើឱ្យយើងអាចរៀនសូត្របានជាច្រើន។<br>□ ឯកភាពទាំងស្រុង □ ឯកភាព □ មិនដឹង □ មិនឯកភាព □ មិនឯកភាពទាល់តែសោះ | 5 4 3 2<br>1 |
| 10 | ធ្វើការក្នុងក្រុមជាមួយមនុស្សស្រី គ្មានបានសម្រេចផលអ្វីទេ។ ពួកគេដូចជាគ្មានគំនិតយោបល់ដែលអាចផ្តល់ឱ្យក្រុមបានសោះ។ ម្យ៉ាងទៀតពួកគេខ្សោយ ហើយអៀនប្រៀនច្រើន មិនស្វាហាប់។<br>□ ឯកភាពទាំងស្រុង □ ឯកភាព □ មិនដឹង □ មិនឯកភាព □ មិនឯកភាពទាល់តែសោះ | 1 2 3<br>4 5 |
| | | |

**<u>ឧបសម្ព័ន្ធ ៦៖</u>**

**របៀបវារៈសម្ភន្ធ របស់ក្រុមយុវវ័យនៅតាមសហគមន៍ (CYG)**

| រយៈពេល | ជំហាន | ប្រធានបទ | ចំនុចគន្លឹះដែលអាចនាំមកនូវជោគជ័យ |
|---|---|---|---|
| ៥ នាទី | | **មតិស្វាគមន៍ និង ការបង្ហាញពីគោលបំណងសិក្ខាសាលា**<br>-អ្នកសម្របសម្រួលចាប់ផ្តើមសិក្ខាសាលាដោយមតិស្វាគមន៍ យ៉ាងកក់ក្តៅដល់សិក្ខាកាមទាំងអស់ហើយរៀបចំដើម្បីធ្វើការណែនាំខ្លួនសិក្ខាកាមទាំងអស់គ្នា។<br>-អ្នកសម្របសម្រួលបន្ទាប់មកបិទប៉ុស្ទ័រលើក្តារខៀនដែលបង្ហាញពីគោលបំណងកម្មវិធីនៃសិក្ខាសាលា ។ សង្ខេបគោលបំណង និងលទ្ធផលរំពឹងទុកនៃសិក្ខាសាលា។ | អ្នកសម្របសម្រួលរៀបចំសរសេរប៉ុស្ទ័រស្តីអំពីគោលបំណងនិងខ្លឹមសារសិក្ខាសាលា ទុកជា មុន។<br>បរិយាកាសស្និទស្នាលបង្កើតនូវទំនុកចិត្ត អំណរសាទរនិងការចូលរួមយ៉ាងសកម្មពីសិក្ខាកាម។ |
| ២០ នាទី | ១ | **ការបោះឆ្នោតដោយសម្ងាត់**<br>-អ្នកសម្របសម្រួលពន្យល់ពីរចនាសម្ព័ន្ធ ទួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការនីមួយៗ ដោយបង្ហាញផ្ទាំងប៉ុស្ទ័រស្តីអំពីរចនា-សម្ពន្ធ័ របស់ក្រុមយុវវ័យនៅតាមសហគមន៍ (ឧបសម្ព័ន្ធ ៤)។<br>-ប្រាប់សិក្ខាកាមថាក្រុមយុវវ័យមានសសមាជិកភាពដូចបានបង្ហាញក្នុងប៉ុស្ទ័រ ហើយប្រធាន និងអនុប្រធាននឹងត្រូវជ្រើសរើសតាមរយៈការបោះឆ្នោត។<br>-រើសយកសមាជិក ៦ នាក់ដែលបានពិន្ទុខ្ពស់ជាងគេ តាមរយៈពាក្យសុំចូលជាសមាជិក ឬស្នើឱ្យសិក្ខាកាមម្នាក់ៗសរសេរឈ្មោះសមាជិកក្រុមយុវវ័យ ៣ នាក់ដែលខ្លួនពេញចិត្ត ដាក់ចូលក្នុងប្រអប់ រួចរើសយកសមាជិក ៦ នាក់ដែលបានពិន្ទុខ្ពស់ជាងគេ។ សរសេរឈ្មោះទាំងនោះលើក្តារខៀន។ វាជាការប្រសើរណាស់ ប្រសិនបើអ្នកទាំងនោះមកពីផ្នែកផ្សេងៗនៃភូមិរបស់ពួកគេ។<br>-ពន្យល់សិក្ខាកាមថា ការបោះឆ្នោតធ្វើឡើងជាលក្ខណៈសម្ងាត់។ នៅពេលរាប់សន្លឹកឆ្នោត អ្នកណាដែលទទួលបានសម្លេងច្រើនជាងគេបំផុតត្រូវបានតែងតាំងជាប្រធាន អ្នកណាដែលទទួលបានសម្លេងច្រើនជាងគេបន្ទាប់ពីទី១ គឺទី២ និង ទី៣ ត្រូវបានតែងតាំងជាអនុប្រធាន។ ដូច្នេះមានន័យថា៣នាក់ក្នុងចំណោម៦ត្រូវបានតែងតាំងជាប្រធានអនុ | អ្នកសម្របសម្រួលបិទប៉ុស្ត័រដែលសរសេរស្រាប់អំពីរចនាសម្ពន្ធ័តួនាទី/ការទទួលខុសត្រូវរបស់ "ក្រុមយុវវ័យនៅតាមសហគមន៍" ដែលបានបង្កើត ឡើងដោយពួកគេ កាលពីសិក្ខាសាលាលើកមុន ទៅលើក្តារខៀន។<br><br>អ្នកសម្របសម្រួលដឹកនាំដំណើរការជ្រើសរើសបេក្ខជន៦នាក់ តាមរយៈពិន្ទុពាក្យសុំចូលជាសមាជិក ឬធ្វើការជ្រើសរើស លើកទី១។<br>ពេលខ្លះតម្រូវ ឱ្យមានការពិភាក្សា គ្នាបន្ថែមទៀតក្នុងការជ្រើសរើសបេក្ខជននេះ។ |

| | | | |
|---|---|---|---|
| | | ប្រធាន ហើយក្រៅពីនោះជាសមាជិក ។<br>អ្នកសម្របសម្រួលចែកបណ្ណ័សតូចមួយសន្លឹកដល់សិក្ខាកាមម្នាក់ៗ ។<br>សិក្ខាកាមទាំងអស់សរសេរឈ្មោះមនុស្សម្នាក់ដែលគេពេញចិត្ត ដោយសម្ងាត់រៀងៗខ្លួន ( គឺជាមនុស្សដែលគេយល់ថាសកម្ម ទទួលការគោរពរាប់អានពីអ្នកភូមិ មានគំនិតឆ្នៃប្រឌិត មានការតាំងចិត្តខ្ពស់ និងជាគំរូល្អដល់អ្នកដទៃ) ។ ដំណើរការនេះត្រូវការពេល ១០ នាទី ។<br>ធ្វើការរាប់សន្លឹកឆ្នោត និង បង្ហាញពីលទ្ធផល ។<br>អ្នកសម្របសម្រួលធ្វើការកត់ត្រាលទ្ធផល ។ | |
| | | **តួនាទី និង ការទទួល ខុសត្រូវរបស់សមាជិកក្រុម**<br>នៅពេលដែលក្រុមធ្វើការជ្រើសរើសប្រធាន អនុប្រធានរួចហើយ អ្នកសម្របសម្រួលបំបែកសិក្ខាកាមជាក្រុមតូច ហើយឱ្យក្រុមនីមួយៗកំណត់តួនាទី និងការទទួលខុសត្រូវរបស់ក្រុមយុវវ័យ ។ លទ្ធផលដែលចេញពីក្រុមត្រូវបានកត់ត្រាលើផ្ទាំងក្រដាសធំ ដែលអ្នកសម្របសម្រួលបានចែកដល់ក្រុមនីមួយៗ ។<br>បិទចម្លើយដែលលើកឡើងដោយសិក្ខាកាមទាំងអស់នៅលើក្ដារខៀនដើម្បីធ្វើការពិនិត្យទាំងអស់គ្នា ។ អ្នកសម្របសម្រួលប្រើសំណួរបំផុសរកចំនុចដែលខ្វះខាតដោយផ្អែកលើតារាងខាងក្រោមឧ: ចំនុច ( លេខ២) មិនត្រូវបានលើកឡើងក្នុងការពិភាក្សាក្រុមទេ ។អ្នកសម្របសម្រួលអាចលើកជាសំនួរតើភារកិច្ច( លេខ២) គួជាភារកិច្ចរបស់សមា-ជិកមួយណា?  បន្ទាប់មកឱ្យសិក្ខាកាមអានតួនាទី និងការទទួលខុសត្រូវរបស់ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមយុវវ័យឡើងវិញ ។ ប្រាប់សិក្ខាកាមថាបញ្ជីឈ្មោះនៃក្រុមយុវវ័យ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមនឹងត្រូវកត់ត្រា  ហើយប្រគល់ជូនសមាគមយុវជនខ្មែរឥស្លាម និងបិទប្រកាសជាសាធារណៈប្រសិនបើ អាចធ្វើទៅបាន ។ | សិក្ខាកាមធ្វើការតាមក្រុម ។<br><br>សិក្ខាកាមឆ្លើយនឹងសំណួរ ។<br><br>សិក្ខាកាមសួរសំណួរបើមានចម្ងល់ ។ |

**<u>ឧបសម្ព័ន្ធ ៧:</u>**

## តួនាទី និង ការទទួលខុសត្រូវនៃសមាជិកម្នាក់ៗ ដែលស្ថិតក្នុងក្រុមយុវវ័យ

**<u>ក្រុមគាំទ្រក្រុមយុវវ័យ</u>**

ផ្តល់ការប្រឹក្សាដល់ក្រុមយុវវ័យ ។

ជួយសម្របសម្រួលដោះស្រាយរាល់បញ្ហាដែលកើតមានឡើង ។

ធ្វើជាប្រធានកិត្តិយស នៃការប្រជុំតាមការអញ្ជើញរបស់ ក្រុមយុវវ័យ ។

ធ្វើជាហិរញ្ញិក (ក្នុងតំណាក់កាលដំបូង បន្ទាប់មកភារកិច្ចនេះនឹងត្រូវផ្ទេរទៅឱ្យក្រុមយុវវ័យ) ។

- O រក្សាទុកថវិកា ដែលទទួលពីសមាគមយុវជនខ្មែរឥស្លាម ។
- O ផ្ទេរការទទួលខុសត្រូវក្នុងការទិញសម្ភារឱ្យទៅអនុប្រធាន នៅពេលដែលប្រធានអវត្តមាន ។
- O ធ្វើការជាមួយប្រធានដើម្បីរៀបចំសំណុំបែបបទទូទាត់ ដូចជាវិក័យប័ត្រសម្រាប់ដាក់ជូនសមាគមយុវជនខ្មែរឥស្លាម ។

**<u>ប្រធាន</u>**

ទទួលខុសត្រូវលើការសម្របសម្រួលសកម្មភាពការងារដែលទាក់ទងជាមួយ ក្រុមយុវវ័យ

ទំនាក់ទំនងជាមួយក្រុមគាំទ្រក្រុមយុវវ័យ/សមាគមយុវជនខ្មែរឥស្លាម ធ្វើអោយប្រាកដថាមានការជួយគាំទ្រគ្រប់គ្រាន់ដល់ក្រុមយុវវ័យ ។

សហការជាមួយសមាជិកក្រុមយុវវ័យដើម្បីធ្វើការកំណត់បញ្ហា និង ដំណើរការអនុវត្ត និង កំណត់នូវដំណោះស្រាយដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលបានកើតឡើង ។

ជួបប្រជុំជាមួយអាណាព្យាបាលសិស្សដែលបានបោះបង់ការសិក្សា ដើម្បីរកមើលមូលហេតុដែលធ្វើអោយកុមារបោះបង់ការសិក្សា ។

ឆែកមើលតម្លៃសម្ភារដែលត្រូវទិញ(ប្រសិនបើចាំបាច់) និង ធ្វើការអនុញ្ញាតរាល់ការទិញទំនិញផ្សេងៗ

ធ្វើការរាយការណ៍ជូនក្រុមគាំទ្រ ក្រុមយុវវ័យ ឬ សមាគមយុវជនខ្មែរឥស្លាមរាងរាល់ខែ ។

ចុះពិនិត្យមើល និង តាដានការអនុវត្តសកម្មភាពការងារ ។

រៀបចំការប្រជុំផ្សេងៗ

**<u>អនុប្រធាន</u>**

ទទួលខុសត្រូវនៅពេលដែលប្រធានអវត្តមាន

ទាក់ទងជាមួយនឹង អ្នកតំណាងសមាគមយុវជនខ្មែរឥស្លាម,តំណាងសហគមន៏

សមាជិកក្រុមយុវវ័យដើម្បីធ្វើការកំណត់ កុមារក្នុង, ក្រៅសាលា និង

យុវវ័យក្រៅសាលាដែលត្រូវការជួយឧបត្ថម្ភគាំទ្រពីក្រុមយុវវ័យ ។

ផ្តល់ឈ្មោះអ្នកទាំងនោះ ដល់ប្រធាន

ចូលរួមក្នុងការអនុវត្តសកម្មភាព ដែលបានកំណត់នៅក្នុងផែនការសកម្មភាព ។

**សមាជិក**

ចូលរួមរាល់ការប្រជុំដែលរៀបចំដោយប្រធានក្រុមយុវវ័យ និង សមាគមយុវជនខ្មែរឥស្លាម

ធ្វើការយ៉ាងជិតស្និទ្ធជាមួយ ប្រធានក្រុមយុវវ័យការកំណត់ កុមារក្នុង ក្រៅសាលា និង យុវវ័យក្រៅសាលាដែលត្រូវការការជួយឧបត្ថម្ភគាំទ្រពីក្រុមយុវវ័យ ។

ចូលរួមក្នុងការអនុវត្តសកម្មភាព ដែលបានកំណត់នៅក្នុងផែនការសកម្មភាព ។

ផ្តល់ពិតមានអំពីអ្នកទទួលផលដល់ក្រុមគ្រួសារ

អាណាព្យាបាលនៃអ្នកទទួលផលទាំងអស់អនុញ្ញាតអោយកុមារចូល រួមធ្វើសកម្មភាពជាមួយក្រុមយុវវ័យ ។

ផ្តល់សំណូមពរផ្សេងៗដល់ក្រុមយុវវ័យអំពីបទពិសោធដែលគេប្រឈមមុខដើម្បីកែលំអរសកម្មភាពផ្សេងៗ

រៀបចំបញ្ជីអ្នកទទួលផលដែលបានចូលរួមក្នុងសកម្មភាពនីមួយៗជាមួយក្រុមយុវវ័យ



**<u>ឧបសម្ព័ន្ធ ៨៖</u>**

## សិក្ខាសាលា ស្តីពីការលើកផែនការសកម្មភាព

| **រយៈពេល** | **ជំហាន** | **ប្រធានបទ** | **ចំនុចដែលនាំមកនូវជោគជ័យ** |
|---|---|---|---|
| ៥ នាទី | | **ស្វាគមន៍ និងការបង្ហាញពីគោលបំណងនៃសិក្ខាសាលា**<br>ពន្យល់ថាសិក្ខាកាម ក្នុងសិក្ខាសាលានេះ យើងនឹងធ្វើផែនការដោយមានការចូលរួម ។ នៅពេលបន្ទាប់ពីនេះ ក្រុមយុវវ័យនឹងអនុវត្តផែនកានេះ ដូច្នេះវាជាផែនទី បង្ហាញផ្លូវក្នុងការអនុវត្តសកម្មភាពរបស់យុវវ័យ ។ | ផ្តល់ការពន្យល់យ៉ាងខ្លីអំពីPLA ដែលមានន័យថាសកម្មភាព សិក្សាដែលមានការចូលរួម ។ |
| ៤៥ នាទី | | **ការបង្ហាញពីបញ្ហាទូទៅ និង ទស្សនៈវិស័យ**( ទស្សនៈសម្រាប់អនាគត)<br>ពន្យល់ថា មុននឹងយើងធ្វើសកម្មភាពអ្វីមួយ យើងគួរតែមានការយល់ច្បាស់ពីស្ថានភាពបច្ចុប្បន្ននៅក្នុងភូមិរបស់យើង ។<br>នៅក្នុងក្រុមធំៗឱ្យសិក្ខាកាមគិតពីបញ្ហាមួយ ឬពីរ ដែលពួកគេយល់ថាជាបញ្ហាជាក់លាក់សម្រាប់ភូមិគេ( បញ្ហាទាក់ទងនឹងកុមារដែលជួបការលំបាកក្នុងការរៀនសូត្រ ឥរិយាបទរបស់ឪពុកម្តាយ និងកុមារខ្លួនឯងផ្ទាល់ចំពោះការអប់រំ បញ្ហាដែលទាក់ទងនឹងយុវវ័យក្រៅសាលា និងបញ្ហាផ្សេងទៀតដូចជាអំពើហឹង្សាក្នុងគ្រួសារ ការជួញដូរកុមារ ការរាលដាលជំងឺអេដ៍ ជម្ងឺផ្តាសាយបក្សី ការប្រើគ្រឿងញៀន និងបញ្ហាសុខភាពផ្សេងទៀត ជាដើម ។ល ។ អ្នកសម្របសម្រួលប្រើរូបភាព ដើម្បីបំផុសគំនិត នៅក្នុងសកម្មភាពនេះ ។ បើមានពេលវេលា ឱ្យសិក្ខាកាមធ្វើការជាក្រុមពី៥-៦នាក់ ពិភាក្សាគ្នារកបញ្ហាដែលមិនទាន់បានលើក ដោយគូររូបភាព ឬសរសេរអក្សរលើប័ណ្ណ ។<br>- ឱ្យពួកគេគិតស្រមៃអំពីការផ្លាស់ប្តូរ នាពេលអនាគត ។<br>ក្រុមនីមួយៗត្រូវគិតថាពួកគេមានពេល៦ខែ ។ពួកគេត្រូវគិតនឹកមើលតើបញ្ហាជាក់លាក់ណាមួយនឹងអាចផ្លាស់ប្តូរទៅជាប្រសើរយ៉ាងណាក្នុងរយៈពេល៦ខែនេះដោយគូរចេញជារូបភាពដើម្បីធ្វើការបង្ហាញពីគំនិតទាំងនោះតំណាងក្រុមនីមួយៗធ្វើការបង្ហាញរូបភាពដោយធ្វើការរៀបរាប់ពីបញ្ហាទាំងឡាយ និង និងទស្សនៈសម្រាប់អនាគតរបស់ពួកគេ *(សកម្មភាពនេះ មិនអាចធ្វើបានក្នុងក្រុមតូចឡើយ បើពេលវេលាមិនគ្រប់គ្រាន់)* ។ បញ្ហាគឺជាអ្វីៗដែលទាក់ទងទៅនឹងកុមារក្នុងសាលា និងកុមារ/យុវវ័យនៅក្រៅសាលា ។ | នៅក្នុងសិក្ខាសាលា PLA មួយ តម្រូវឱ្យមានអ្នកសម្របសម្រួលយ៉ាងតិចចំនួន២នាក់ដើម្បីជួយសម្របសម្រួលក្រុមតូច ដែលមានគ្នាពី ៩-១០នាក់ ។ សមាជិកក្នុងក្រុមគួរតែជាអ្នកធ្លាប់មានទំនាក់ទំនងគ្នាពីមុន ឧ:អ្នករស់នៅជិតខាងគ្នា គួរចូលរួមក្នុងក្រុមពិភាក្សាជាមួយគ្នា ។<br><br>ត្រូវមានអាហារសម្រន់ ទឹកសម្រាប់សិក្ខាកាមនៅពេលសម្រាក ។ ពុំនោះទេសិក្ខាកាមនឹងហេវហត់ ហើយមិនអាចចូលរួមមានយោបល់បានផុលផុសឡើយ ។<br><br>រៀបចំអង្គុយលើកន្ទេល ឬកម្រាលផ្ទាល់ជាវិធីមួយល្អដែលសិក្ខាកាមអាចអង្គុយតាមឥរិយាបទដែលគេចង់ ។ |

| | | | |
|---|---|---|---|
| | | -អ្នកសម្របសម្រួលធ្វើការកត់ត្រាបញ្ហា និងការស្រមៃរបស់សិក្ខាកាម ដោយសរសេរបញ្ហាមួយលើបណ្ណ័មួយសន្លឹក ។<br>-អ្នកសម្របសម្រួលធ្វើការបូកសរុប ។ អ្នកសម្របសម្រួលពន្យល់ថា: ដោយមានការជួយគាំទ្រពីក្រុមគាំទ្រ នោះក្រុមយុវវ័យនឹងដើរតួនាទីយ៉ាងសំខាន់ គឺជាភ្នាក់ងារក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរស្ថានភាពទាំងនោះ ។<br>*សំគាល់*: បណ្ណ័ទាំងនេះនឹងត្រូវយកទៅប្រើក្នុងសកម្មភាពក្រោយ ។ | |
| ៣០ នាទី | | **ការរៀបប័ណ្ណទៅតាមប្រភេទ( ការកំណត់អាទិភាពបញ្ហាទាំងឡាយនៅក្នុងភូមិ)**<br>-សិក្ខាកាមត្រូវបានបែងចែកជាពីរក្រុម ក្រុមនីមួយៗមានគ្នា ៩-១០ ហើយមានអ្នកសម្របសម្រួលម្នាក់ ។ ក្រុមនីមួយៗមានស្ត្រី និង បុរសចម្រុះគ្នា ។<br>-ក្រុមនីមួយៗត្រូវបានទទួលបណ្ណ័បញ្ហាមួយសម្រាប់ (សរសេរដោយអ្នកសម្របសម្រួលផ្អែកលើលទ្ធផលនៃការពិភាក្សាពីមុន) ។ ពួកគេត្រូវបែងចែកបណ្ណ័ទាំងនោះជាពីរផ្នែកមួយផ្នែកជាបញ្ហាទាក់ទងនឹងកុមារក្នុងសាលា និងមួយផ្នែកទៀតជាបញ្ហារបស់កុមារ/យុវវ័យក្រៅសាលា ។ យកបណ្ណ័បញ្ហាទាំងនោះ ទៅបិទលើក្រដាស់ធំដែលបានបត់ជាពីរ ដែលមួយផ្នែកតាងឱ្យបញ្ហាកុមារនៅក្នុងសាលា និងមួយផ្នែកទៀតតាងបញ្ហាកុមារ/យុវវ័យក្រៅសាលា ។<br>បន្ទាប់មក ក្រុមនេះចែកចេញជាពីរអនុក្រុមដែលមានគ្នា៤ -៥នាក់ ។ អនុក្រុមមួយ គឺតអំពីបញ្ហាកុមារក្នុងសាលា និង ក្រុម មួយទៀតគិតពីបញ្ហាកុមារ/យុវវ័យក្រៅសាលាដែលមិនទាន់បានលើកឡើងពីមុន តែវាជាបញ្ហាទូទៅនៅក្នុងភូមិរបស់ពួកគេ ។ ពួកគេអាចគូររូបភាព ឬ សរសេរពីបញ្ហាទាំងនោះក៏បាន ។<br>អនុក្រុម( ៤-៥) នេះត្រឡប់ចូលមកក្នុងក្រុមតូច( ៩-១០) ដូចមុនវិញ ។ តំណាងក្រុមនីមួយៗធ្វើការបង្ហាញនូវគំនិតបន្ថែមក្នុងក្រុមនេះ ហើយ គំនិតទាំងនោះត្រូវបានបន្ថែមទៅលើក្រដាសធំ ។ ប័ណ្ណដែលដូចគ្នាទុកតែមួយ ។ | ឧទាហរណ៍:<br><br> |

<table>
<tr>
<td></td>
<td></td>
<td>-សិក្ខាកាមត្រូវទទួលបានផ្កាយដែលមានទំហំផ្សេងគ្នា គឺទំហំធំ មធ្យម និង តូច ។ នៅក្នុងក្រុម សហការគ្នាក្នុងការសម្រេចចិត្តថាតើបញ្ហាណាមួយ ដែលកើតមានទូទៅនៅក្នុងភូមិជាងគេ (ដាក់ផ្កាយធំ) មានជាមធ្យម (ដាក់ផ្កាយទំហំ មធ្យម) បញ្ហាដែលកើតមានតិចតួច (ដាក់ផ្កាយតូច) ។<br>-ក្រុមត្រូវជួយគ្នាធ្វើរបៀបនេះ ទាំងបញ្ហាកុមារនៅក្នុងសាលា និង បញ្ហាកុមារ/យុវវ័យនៅក្រៅសាលា ។នៅ ក្នុងក្រុម(៩-១០នាក់)សិក្ខាកាមម្នាក់ៗទទួលទទួលបានគ្រាប់ឡេវអាវពីរគ្រាប់  ពួកគេប្រើគ្រាប់ឡេវអាវនេះដើម្បីបោះឆ្នោតរើសយកបញ្ហា២ ដែលសំខាន់ ។<br>-នៅក្នុងដំណាក់កាលនេះអ្នកសម្របសម្រួលរំលឹកដល់ក្រុមនីមួយៗថា នៅពេលធ្វើការបោះឆ្នោតជ្រើសរើសនេះ ពួកគេត្រូវគិតថាត្រូវរើសយកបញ្ហាណាដែលអាចដោះស្រាយបានដោយសហគមន៍/ពួកគេដោយសហការជាមួយសមាគមយុវជនខ្មែរតស្លាមក្នុងគម្រោងដែលត្រូវការថវិកា xx ដុល្លា ផ្តល់ដោយសមាគមយុវជនខ្មែរតស្លាម ។ពួកគេធ្វើរបៀបនេះ ទាំងលើបញ្ហាកុមារនៅក្នុងសាលា និងបញ្ហាកុមារ/យុវជន ក្រៅសាលា ។<br><u>សំគាល់:</u> បញ្ហាមួយគឺអាចបោះបានតែឡេវអាវមួយគ្រាប់ ក្នុងម្នាក់ ។ បញ្ហាចំនួនពីរដែលប្រឈមមុខដោយក្រុមកុមារក្នុងសាលា និងកុមារ/យុវវ័យក្រៅសាលាត្រូវបានរើសចេញតាមការយល់ឃើញរបស់ក្រុមទាំងពីរ ។<br>តំណាងក្រុមនីមួយៗធ្វើការបង្ហាញការសម្រេចចិត្តដលក្រុមធំទាំងមូល ។</td>
<td>


</td>
</tr>
<tr>
<td>៦០ នាទី</td>
<td>៣</td>
<td>ដំណោះស្រាយ និង ប្រភពជំនួយ<br>-សិក្ខាកាមធ្វើការជាក្រុមដែលមានគ្នាពី ៩-១០នាក់ជាថ្មីម្តងទៀតនៅក្នុងក្រុម(៩-១០នាក់ ) នេះធ្វើការចែកជា២ក្រុមទៀត ដែលមានគ្នាពី ៤ទៅ៥នាក់ ។ ក្រុមមួយត្រូវសុំអោយធ្វើការពិភាក្សាលើបញ្ហា  កុមារនៅក្នុងសាលា និង ក្រុមតូចមួយទៀត សុំអោយធ្វើការពិភាក្សាលើ បញ្ហាកុមារ/យុវវ័យនៅក្រៅសាលា ។<br>-ក្រុមនីមួយៗបិទបញ្ហាលើក្រដាសធំដែលចែកជា ៣ជួរ ( គឺជួរបញ្ហា មូល-ហេតុ និងដំណោះស្រាយ) ។<br>-អ្នកសម្របសម្រួលផ្តល់ក្រដាសស និង ហ្វឺតដល់ក្រុមនីមួយៗ ដើម្បីឱ្យគេ គួរឬសរសេរពីមូលហេតុនៃបញ្ហា ។</td>
<td><table>
<tr><td>បញ្ហា</td><td>មូលហេតុ</td><td>ដំណោះ</td></tr>
<tr><td rowspan="3"></td><td></td><td></td></tr>
<tr><td></td><td></td></tr>
<tr><td></td><td></td></tr>
<tr><td rowspan="3"></td><td></td><td></td></tr>
<tr><td></td><td></td></tr>
<tr><td></td><td></td></tr>
</table></td>
</tr>
</table>

-ក្នុងក្រុមសិក្ខាកាមបន្តការពិភាក្សា លើដំណោះស្រាយដោយគូរ ឬសរសេរ ហើយដាក់លើក្រដាសធំសម្រាប់ធ្វើការបូកសរុប ។

-ដោយប្រើផ្កាយដើម្បីធ្វើការកំណត់ដំណោះស្រាយដែលគេពេញចិត្ត ហើយដែលអាចដោះស្រាយបានតាមរយៈការចូលរួមពីសហគមន៍ ។ ( ផ្កាយធំ = បញ្ហាដែលអាចដោះស្រាយបានដោយយុវវ័យ ជាមួយការចូលរួមយ៉ាងខ្លាំងក្លាពីសហគមន៍ ផ្កាយមធ្យម=បញ្ហាដែលអាចដោះស្រាយបានដោយយុវវ័យ ជាមួយការចូលរួមមួយចំនួនណាមួយពីសហគមន៍  ផ្កាយតូច=បញ្ហាដែលមិនអាចដោះស្រាយបានដោយយុវវ័យ ឬក៏ដោយសហគមន៍បានទេ ។

-ដំណោះស្រាយគឺត្រូវនិយាយលំអិតៈ ធ្វើអ្វី? អ្នកណា? នៅពេលណា? នៅទីណា?និង ធ្វើដូចម្តេច? ។

-បន្ទាប់មកក្រុម(៤-៥នាក់) ចូលរួមមកក្រុមដើម(៩-១០នាក់)វិញ ហើយតំណាងក្រុម(៤-៥នាក់)បង្ហាញគំនិតក្នុងក្រុម(៩-១០នាក់) ហើយធ្វើការបូកសរុបគំនិតដែលបានព្រមព្រៀងលើក្រដាសធំ ។

-ក្រុម(៩-១០នាក់) បង្ហាញបញ្ហា និង ដំណោះស្រាយដល់អង្គសិក្ខាសាលាទាំងមូល ។

| បញ្ហា | មូលហេតុ | ដំណោះ |
|---|---|---|
| | | ★ (ធំ) |
| | | ★ (មធ្យម) |
| | | ★ (តូច) |



២០នាទី | ៤

**ការប៉ាន់មើលជម្រើសនានា**

-ក្រុមទាំងពីរមករួមគ្នាវិញ ដើម្បីធ្វើការបោះឆ្នោតជ្រើសរើសយក បញ្ហាមួយរបស់កុមារនៅក្នុងសាលា ដែលមានដំណោះស្រាយឬជម្រើស២ និង បញ្ហាមួយរបស់កុមារ/យុវវ័យនៅក្រៅសាលា ដែលមានដំណោះស្រាយឬជម្រើស១ ។ ប្រើគ្រាប់សណ្តែកដើម្បីបំពេញទម្រង់ប៉ាន់ស្មាន ដែលមាន ទិដ្ឋភាព ៥ ផ្សេងគ្នា ដូចជាៈ អស់ថវិកាតិច  ប្រើពេលខ្លី  លទ្ធភាពអាចធ្វើទៅបាន ការចូលរួមរបស់សហគមន៍ កុមារ/យុវវ័យងាយរងគ្រោះអាចទទួលផល ។

| បញ្ហា | ដំណោះ | ទិដ្ឋភាព | | | | |
|---|---|---|---|---|---|---|
| | | ១<br>ថវិកាតិច. | ២<br>ប្រើពេលខ្លី | ៣<br>អាចធ្វើបាន | ៤<br>ការចូលរួម | ៥<br>កុមារ<br>ទទួលផល |
| | ១ | ●●● | ●●● | ●●● | ●●● | ●● |
| | ២ | ● | ●● | ●● | ●●● | ●● |
| | ៣ | ●● | ●● | ● | ●● | ●● |

សិក្ខាកាមអង្គុយជារង្វង់លើកំរាល ។ ផ្ទាំងក្រដាសធំដាក់ចំកណ្តាលរង្វង់ ដើម្បីងាយស្រួលក្នុងការពិភាក្សា ។

<table>
<tr><td></td><td></td><td>
<table>
<tr><td></td><td>៤</td><td>●</td><td>●</td><td>●●</td><td>●●</td><td>●●</td></tr>
<tr><td></td><td>៥</td><td>●</td><td>●●</td><td>●●</td><td>●</td><td>●</td></tr>
<tr><td></td><td>១</td><td>●</td><td>●●●</td><td></td><td></td><td></td></tr>
<tr><td></td><td>២</td><td>●●</td><td>●</td><td></td><td></td><td></td></tr>
</table>
បញ្ហា របស់កុមារនៅក្នុងសាលា<br>
បញ្ហាកុមារ/យុវវ័យនៅក្រៅសាលា<br>
ដើម្បីធ្វើការកំណត់វគ្គសិក្សានេះអ្នកសម្របសម្រួលត្រូវធ្វើការពន្យល់យ៉ាងច្បាស់លាស់ដល់ក្រុម លើការបាន់ប្រមាណមើលទិដ្ឋភាពផ្សេងៗ និង ពិសេសលើថវិកា ពេលវេលា ប្រសិនបើទិដ្ឋភាពណាមួយដែលយើងពេញចិត្តខ្លាំង ឧៈក្រុមមានការឯកភាពគ្នាថាដំណោះស្រាយទី១ ទិដ្ឋភាពទី១ ប្រើប្រាស់ថវិកាតិច ត្រូវដាក់គ្រាប់សណ្តែក៣គ្រាប់ ចំណែកឯ ដំណោះស្រាយទី១ ទិដ្ឋភាពទី២<br>
ប្រើប្រាស់ពេលវេលា មធ្យម ត្រូវដាក់គ្រាប់សណ្តែកតែ២។<br>
ធ្វើការពិភាក្សាពីលទ្ធផល និង សម្រេចចិត្តលើដំណោះស្រាយដែលពេញចិត្តបំផុតគឺ<br>
- ដំណោះស្រាយ ២ នៃបញ្ហារបស់កុមារនៅក្នុងសាលា ជាមួយ<br>
- ដំណោះស្រាយ១នៃបញ្ហារបស់ កុមារ/យុវវ័យនៅក្រៅសាលា</td><td></td></tr>
<tr><td>២ម៉ោង</td><td>៥</td><td>ការសរសេរផែនការសកម្មភាព<br>
-អ្នកសម្របសម្រួល២នាក់និងជួយធ្វើការសម្របសម្រួលក្រុម២ ដើម្បីសរសេរផែនការសកម្មភាព។<br>
-ជំហាននៃការធ្វើផែនការសកម្មភាពៈ ១) ការដាក់កាលបរិច្ឆេទនៃការសសេរផែនការ សកម្មភាព ដាក់ឈ្មោះភូមិ ឃុំ ២) បញ្ហា ៣) ជំរើសនានា ៤) ការពិពណ៌នាពីសកម្មភាព។ សកម្មភាពត្រូវនិយាយលំអិតនិងចាល់លាក់ (ធ្វើអ្វី អ្នកណាជាអ្នកធ្វើ ហើយអ្នកណាចូលរួម ធ្វើនៅពេលណា ធ្វើនៅទីណា និងធ្វើយ៉ាងដូចម្តេច) និង ៥) ផលរំពឹងទុក។<br>
-ការប៉ាន់ប្រមាណមើលតម្លៃនៃសម្ភារ ឬ កំណត់ធនធានក្នុងមូលដ្ឋាន។<br>
-បង្ហាញ ផែនការដល់អង្គសិក្ខាសាលាទាំងមូល។<br>
សំគាល់ ៖ ក្រៅពីសិក្ខាសាលាធ្វើផែនការ សមាជិកទាំងអស់ត្រូវចូលរួមការប្រជុំ ២ដងក្នុងមួយខែ ដោយមានប្រធានក្រុមជាអ្នកដឹកនាំការប្រជុំ ដើម្បីធ្វើការពិនិត្យតាមដានទៅលើការអនុវត្តផែនការ ដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមាន។<br>
<u>សំគាល់:</u> CIYAចាត់តាំងអ្នកទទួលបន្ទុកម្នាក់ ដើម្បីតាមពិនិត្យមើលដំណើរការ</td><td>សមាជិកនៃ CYG ត្រូវរក្សាផែនការសកម្មភាពនេះទុក។ មានជម្រើស ៣ដើម្បីអនុវត្តសកម្មភាព។ សមា ជិក៦-៧នាក់ (រួមជាមួយអនុប្រធានម្នាក់) នឹងទទួលខុសត្រូវលើសកម្មភាពសំខាន់១ហើយការងារលំអិតផ្សេងទៀតត្រូវប្រគល់ឱ្យសមាជិកណាម្នាក់អាស្រយ័ទៅតាមជំនាញ និងចំណាប់អារម្មណ៍របស់គេ។</td></tr>
</table>

| | | | |
|---|---|---|---|
| | | សកម្មភាព ហើយធ្វើជាអ្នកទំនាក់ទំនងក្នុងការផ្ដល់ពិតមានត្រឡប់ មក CIYA វិញ ។ ថវិកាត្រូវទម្លាក់តាមអ្នកទទួលបន្ទុកហើយអនុប្រធាន ដែលទទួលបន្ទុកហេរញ្ញិកអាចបើកប្រាក់ជាមុនខ្លះសម្រាប់ដំណើរការ ។ | |

## ផែនការសកម្មភាព

## រៀបចំដោយក្រុមយុវវ័យ

**ភូមិ:**..............................................................

**ឃុំ:** ............................................................

| បញ្ហា | ជំរើស | សកម្មភាពលំអិត | អ្នកណា | នៅពេលណា/រយ:ពេល | នៅទីណា | ធនធាន ឬថវិកា | លទ្ធផលរំពឹងទុក |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

ឈ្មោះអ្នកចូលរួមធ្វើផែនការ:

១..............................................................

២..............................................................

៣..............................................................

៤..............................................................

៥..............................................................

៦..............................................................

៧............................................................

៨..............................................................

.................................

**ឧបសម្ព័ន្ធ ៩:**

## ទម្រង់ផ្ដល់ពត៌មានត្រឡប់របស់ក្រុមយុវវ័យ
## អំពីការចូលរួមក្នុងក្រុមយុវវ័យ

*ការណែនាំ:* ទម្រង់នេះត្រូវចែកឱ្យសមាជិកក្រុមយុវវ័យម្នាក់ៗបំពេញរៀងៗខ្លួន បន្ទាប់ពីធ្វើការពន្យល់ម្ដងមួយចំណុចៗរួចហើយ ។

១. តើអ្នកយល់ថាកម្មវិធីក្រុមយុវវ័យមានប្រយោជន៍ ឬទេ? ☐ បាទ /ចាស ☐ ទេ

២. តើអ្នកយល់ថា ការចូលរួមជាសមាជិកក្នុងក្រុមយុវវ័យ:

| ជាច្រើន | ខ្លះដែរ | ទេគ្មានសោះ | |
|---|---|---|---|
| ☐ | ☐ | ☐ | បានធ្វើអ្វីដែលសប្បាយៗ កម្រិតណា? |
| ☐ | ☐ | ☐ | បានរៀនសូត្រពីអ្វីមួយថ្មីដែលនិយាយពីការចូលរួមរបស់យុវវ័យ កម្រិតណា? |
| ☐ | ☐ | ☐ | បានរៀនសូត្រអ្វីដែលថ្មី ដើម្បីអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន ហើយចូលរួមសកម្មភាពអភិវឌ្ឍសហគមន៍ កម្រិតណា? |
| ☐ | ☐ | ☐ | បានទទួលការរាប់អានពីអ្នកដទៃ កម្រិតណា? |
| ☐ | ☐ | ☐ | មានឱកាសដើម្បីបង្ហាញគំនិតខ្លួនឯងដល់អ្នកដទៃ កម្រិតណា? |
| ☐ | ☐ | ☐ | បានរួមចំណែកមានយោបល់ និងផ្លាស់ប្ដូរបទពិសោធន៍ ក្នុងការប្រជុំនានា កម្រិតណា? |
| ☐ | ☐ | ☐ | អ្នកដទៃស្ដាប់អ្នកកម្រិតណា ពេលអ្នកមានយោបល់? |
| ☐ | ☐ | ☐ | មានឱកាសជួបជាមួយយុវវ័យផ្សេងទៀតដែលអ្នកមិនធ្លាប់ជួបឬស្និទ្ធស្នាលពីមុនមក កម្រិតណា? |
| ☐ | ☐ | ☐ | ដំណើរការក្រុមយុវវ័យទាក់ទាញអ្នកឱ្យចង់ចូលរួមកម្រិតណា? ។ |

២. តើអ្វីដែលអ្នកចូលចិត្តច្រើនជាងគេបំផុតក្នុងកម្មវិធីនេះ ?

៣. តើអ្វីដែលអ្នកចូលចិត្តតិចតួចបំផុត ក្នុងកម្មវិធីនេះ ?

៤. តើអ្នកគិតថា អ្នកអាចចូលរួមអនុវត្តផែនការសកម្មភាព ដោយប្រើពេលវេលាទំនេររបស់អ្នក ក្នុងរយៈពេល១ម៉ោងក្នុងមួយថ្ងៃ ហើយពីរឬបីថ្ងៃក្នុងមួយសប្ដាហ៍ (ដូចជាជួយបង្រៀនកុមារនៅតាមភូមិក្បែរៗផ្ទះអ្នក) ដោយស្ម័គ្រចិត្ត និងមិនទាមទារប្រាក់កម្រៃពីកម្មវិធីបានឬទេ?

☐ បាន ☐ ទេ

៥. តើអ្នកគិតថាអ្វីដែលអាចជួយគាំទ្រដល់អ្នក ដើម្បីឱ្យចូលរួមនៅក្នុងសហគមន៍របស់អ្នក?

- ☐ ផ្ដល់ឱកាសញឹកញាប់ ក្នុងការចូលរួមការប្រជុំ ឬសិក្ខាសាលា
- ☐ បង្កើតក្រុមយុវវ័យ
- ☐ ផ្ដល់ការហ្វឹកហ្វឺនជំនាញដល់យុវវ័យ
- ☐ ផ្សេងៗ(សូមបញ្ជាក់)៖..........................................................................................................

<u>ការចាប់អារម្មណ៍ទូទៅរបស់យុវវ័យ:</u>